01085324



ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 10-Mar-2015, 11:49
CMS/CFO: Sann Rada

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

**អង្គជំនុំជម្រះសាលាដំបូង**
Trial Chamber
Chambre de Premiere instance

# <u>កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចប្រជុំរៀបចំសវនាការ</u>
# <u>សាធារណៈ</u>

សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជសង

**ថ្ងៃទី០៥ ខែមីនា ឆ្នាំ២០១៥**

**ម៉ោង ១៣:៤១នាទី**

**ចៅក្រមសាលាដំបូង៖**

ចៅក្រម និល ណុន ជាប្រធាន

ចៅក្រម ក្លូឌា ហ្វេនស៍
*(Judge Claudia FENZ)*

ចៅក្រម យ៉ា សុខន

ចៅក្រម ហ្សង់ម៉ាក ឡាវែន៍
*(Judge Jean-Marc LAVERGNE)*

ចៅក្រម យូរ ឧត្តរា

ចៅក្រម ធូ មណី (បម្រុង)

ចៅក្រម ម៉ាទីន ខារ៉ុបគីន (បម្រុង)
*(Judge Martin KAROPKIN)*

**ក្រឡាបញ្ជីសាលាដំបូង៖**

លោក ម៉ាធូវ ម៉ាកាធី *(Mr.Matthew Mccarthy)*

កញ្ញា ជា ស៊ីវហ៊ាង

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោក នីកូឡាស គូមជែន
*(Mr.Nicolas KOUMJIAN)*

កញ្ញា សុង ឆវ័ន្ត

លោក ឌេល លីសាក់ *(Mr.Dale LYSAK)*

លោក ចូសេហ្វ អេនឌ្រូ ប៊ យលី
*(Mr. Joseph Andrew BOYLE)*

**មេធាវីការពារជនជាប់ចោទ នួន ជា៖**

លោក សុន អរុណ

លោក សួន វិសាល

លោក វ៉ិចទ័រ កូប៉េ *(Mr.Victor KOPPE)*

**មេធាវីការពារជនជាប់ចោទ ខៀវ សំផន៖**

លោក គង់ សំអុន

**មេធាវីប្រចាំការលោក ខៀវ សំផន៖**

លោកស្រី ទូច វរល័ក្ស

លោក ខលវីន សោនដឺស៍

*(Mr Calvin SAUNDERS)*

**មេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី៖**

លោកស្រី ម៉ារី ហ្គីរ៉ូដ៍ *(Ms.Marie GUIRAUD)*

លោក ឡៅ ជុនធី

លោក ហុង គឹមសួន

លោកស្រី ទី ស្រ៊ីនណា

លោកស្រី ស៊ីន សុវ៉ន

លោកស្រី ជេត វណ្ណលី

លោក វ៉េន ពៅ

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក អ៊ុំ អរុណ

លោកស្រី ស្វ សុទ្ធារី

## បញ្ជីឈ្មោះអ្នកនិយាយ៖

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| អ្នកនិយាយ | ភាសា |
|---|---|
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំ) | ខ្មែរ |
| ចៅក្រម ក្លូឌា ហ្វេនស៍ | អង់គ្លេស |
| លោក នីកូឡាស គូមជែន | អង់គ្លេស |
| លោក ឌេល លីសាក់ | អង់គ្លេស |
| លោក គង់ សំអុន | ខ្មែរ |
| លោក វ៉ិចទ័រ កូប៉េ | អង់គ្លេស |
| លោកស្រី ម៉ារី ហ្គីរ៉ូដ៍ | បារាំង |

# កិច្ចដំណើរការនីតិវិធី

[១៣:៤១:២៩]

**ប្រធានអង្គជំនុំ៖**

អញ្ជើញអង្គុយចុះ!

ក្នុងនាមជាប្រធាន និងជំនួសមុខឲ្យចៅក្រមទាំងអស់នៃអង្គជំនុំជម្រះសាលាដំបូង ខ្ញុំសូមស្វាគមន៍ដល់សហព្រះរាជអាជ្ញា សហព្រះរាជអាជ្ញារង សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី មេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី មេធាវីការពារក្ដី នួន ជា មេធាវីការពារក្ដី ខៀវ សំផន ដែលមានវត្តមាននៅក្នុងកិច្ចប្រជុំរៀបចំសវនាការនៅរសៀលនេះ។ អនុលោមតាមវិធាន៧៩ អនុវិធាន ៧ នៃវិធានផ្ទៃក្នុង អ.វ.ត.ក កិច្ចប្រជុំរៀបចំសវនាការត្រូវធ្វើឡើងជាសម្ងាត់។ លើកលែងតែអង្គជំនុំជម្រះសាលាដំបូងសម្រេចផ្សេងពីនេះ។

អង្គជំនុំជម្រះបានទទួលសំណើពីមេធាវីការពារក្ដី នួន ជា និងមេធាវីការពារក្ដី ខៀវ សំផន ដែលបានស្នើសុំឲ្យធ្វើកិច្ចប្រជុំរៀបចំសវនាការនេះជាសាធារណៈ។ សហព្រះរាជអាជ្ញា និងសហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណីមិនបានជំទាស់ទៅនឹងសំណើសុំនេះទេ។ ប៉ុន្តែស្នើឲ្យមានការធានាចំពោះភាពសម្ងាត់នៃដំណើរការស៊ើបអង្កេតក្នុងសំណុំរឿង០០៣ និង ០០៤។

អង្គជំនុំជម្រះសាលាដំបូងសម្រេចថា កិច្ចប្រជុំរៀបចំសវនាការនេះនឹងធ្វើជាសាធារណៈដោយហេតុថា វាជាប្រយោជន៍ដល់សាធារណជន។ សេចក្ដីសម្រេចនេះធ្វើឡើងនៅក្នុងលក្ខខណ្ឌមួយដែលថាការពិភាក្សាមិនត្រូវរំលោភដល់ភាពសម្ងាត់នៃដំណើរការស៊ើបអង្កេតនៅក្នុងសំណុំរឿង០០៣ និង ០០៤ឡើយ។ អង្គជំនុំជម្រះកត់សម្គាល់ថា សហព្រះរាជអាជ្ញាស្ថិតនៅក្នុងតួនាទីដ៏សមស្របបំផុតមួយដែលអាចកំណត់អំពីការពិភាក្សាណាមួយ ដែលអាចរំលោភដល់ភាពសម្ងាត់នៃដំណើរការស៊ើបអង្កេតនេះ ដោយសារតែសហព្រះរាជអាជ្ញាអាចចូលមើលសំណុំរឿង០០៣, ០០៤បាន។ ហេតុដូច្នេះ អង្គជំនុំជម្រះសូមរំឭកដល់សហព្រះរាជអាជ្ញាឲ្យជូនដំណឹងដល់អង្គជំនុំជម្រះ ប្រសិនបើមានព័ត៌មានណាមួយដែលអាចរំលោភដល់ភាពសម្ងាត់នៃសំណុំរឿង០០៣ និង ០០៤ ក្នុងអំឡុងពេលនៃកិច្ចប្រជុំរៀបចំសវនាការនេះ។

កាលពីម្សិលមិញ មេធាវីការពារក្ដី នួន ជា បានផ្ដល់ជូនជាលក្ខណៈក្រៅផ្លូវការដល់អង្គជំនុំជម្រះ និងភាគីនានានូវសំណៅនៃសំណើសុំមួយពាក់ព័ន្ធនឹងការដាក់បង្ហាញកំណត់ហេតុ ពីសំណុំរឿង

០០៣ និង ០០៤។ សំណើសុំនេះបានដាក់នៅថ្ងៃនេះ ជាភាសាអង់គ្លេស និងជាភាសាខ្មែរ។ នៅក្នុងសំណើរបស់ខ្លួន មេធាវីការពារក្តី នួន ជា បានស្នើដល់អង្គជំនុំជម្រះសាលាដំបូងក្នុងចំណោមបញ្ហាផ្សេងៗ ឲ្យកំណត់កាលបរិច្ឆេទសម្រាប់កិច្ចប្រជុំរៀបចំសវនាការ ដើម្បីសម្របសម្រួលដល់ភាគីធ្វើការពិភាក្សាទៅលើដំណើរការដាក់បង្ហាញកំណត់ហេតុដែលមានជាបន្តបន្ទាប់ និងដើម្បីពិនិត្យមើលវិធីសាស្រ្តសមស្របដែលត្រូវអនុវត្តនាពេលអនាគត។

[១៣:៤៥:០២]

មេធាវីការពារក្តី នួន ជា ក៏បានស្នើសុំឲ្យផ្អាកសវនាការស្តាប់សក្ខីកម្មសាក្សីដែលមានរហស្សនាម 2-TCW-803 និង 2-TCW-809 ផងដែរ។ ក្រោយពីបានស្តាប់ការលើកឡើងដោយសង្ខេបរបស់ភាគីទៅលើការផ្អាកសវនាការស្តាប់សក្ខីកម្មសាក្សី 2-TCW-803 អង្គជំនុំជម្រះបានជម្រាបដល់អង្គ -- ដល់ភាគី តាមរយៈអ៊ីម៉ែល និងការជម្រាបជូនបន្ថែមកាលពីព្រឹកមិញនេះ ថាថ្ងៃនេះអង្គជំនុំជម្រះ នឹងមិនស្តាប់សក្ខីកម្មសាក្សីដែលមានរហស្សនាម 2-TCW-803 ដូចដែលបានកំណត់កាលបរិច្ឆេទ កាលពីមុននោះទេ។ ហើយជាជំនួសវិញ អង្គជំនុំជម្រះនឹងរៀបចំកិច្ចប្រជុំរៀបចំសវនាការមួយ ដើម្បីអនុញ្ញាតឲ្យភាគីបានមាន បានពេញលេញទៅនឹង -- ទៅលើដំណើរការដាក់បង្ហាញកំណត់ហេតុពីសំណុំរឿង០០៣ និង ០០៤ ដែលកំពុងតែមានជាបន្តបន្ទាប់។ ហើយនៅក្នុងកិច្ចពិភាក្សានេះ អង្គជំនុំជម្រះផ្តល់ជូននូវភាគីនីមួយៗមានរយៈពេល ២០នាទីដើម្បីឡើងធ្វើសេចក្តីសន្និដ្ឋានរបស់ខ្លួន។

ហើយជាដំបូងនេះ អង្គជំនុំជម្រះសូមផ្តល់វេទិកាជូនទៅមេធាវីការពារក្តី នួន ជា មុនភាគីដទៃទៀត ពីព្រោះជាម្ចាស់សំណើ។

សូមអញ្ជើញៗ លោកក្រុមមេធាវីការពារក្តីលោក នួន ជា!

[១៣:៤៦:៣៨]

**លោក វ៉ិចទ័រ កូប៉េះ**

សូមអរគុណលោកប្រធាន។ សូមជម្រាបសួរលោក លោកស្រីចៅក្រម។ នៅថ្ងៃនេះ ក្រុមរបស់ខ្ញុំបានដាក់ញត្តិដូចដែលលោកប្រធានបានបញ្ជាក់រួចហើយ ពាក់ព័ន្ធទៅនឹងការបង្ហាញនូវកំណត់ហេតុស្តាប់ចម្លើយពីសំណុំរឿង០០៣ និង ០០៤ ចូលទៅក្នុងសំណុំរឿង។ យើងធ្វើដូច្នេះព្រោះយើងចង់ឲ្យប្រាកដថា អង្គជំនុំជម្រះយល់យ៉ាងច្បាស់អំពីស្ថានភាពដែលយើងកំពុងតែប្រឈម។ ហើយអង្គជំនុំជម្រះអាចសម្រេចថាតើត្រូវធ្វើដូចម្តេចឲ្យបានល្អដូចចំណុច។ យើងធ្វើដូច្នេះដោយសារតែព័ត៌មានដែល

ព្រះរាជអាជ្ញាបានផ្តល់ឲ្យយើងអំពីការបង្ហាញហ្នឹង គឺវាផ្តល់នូវរូបភាពមួយខុសអំពីអ្វីដែលពួកគេមានឥទ្ធិពលចំពោះពួកយើង។ យើងដាក់សារណានេះ ហើយខ្ញុំធ្វើការលើកឡើងនូវសារណានេះ ដោយសារតែខ្ញុំចង់ឲ្យលោកយល់អំពីការប្រឈមយ៉ាងខ្លាំង ព្រមទាំងភាពលំបាកដោយថាការបង្ហាញឯកសារនេះបានបង្កើតឡើងសម្រាប់ពួកយើងខ្ញុំក៏ដូចជាភាគី និងការជំនុំជម្រះនេះ។

ខ្ញុំព្យាយាមលើកឡើងនូវការលំបាកទាំងអស់នេះ តាមរយៈការលើកសារណាផ្ទាល់មាត់នៅក្នុងការជំនុំ -- នៅក្នុងដំណាក់កាលនេះ។ ប៉ុន្តែដោយសារតែអង្គជំនុំជម្រះបានជម្រាបថា ឥឡូវនេះ អង្គជំនុំជម្រះកំពុងតែពិចារណា អំពីវិធីសាស្ត្រដើម្បីដំណើរការទៅមុខ យើងចង់ផ្តល់ព័ត៌មានទាំងអស់នេះជូនចំពោះអង្គជំនុំជម្រះ ក៏ដូចជាភាគីនានា ដើម្បីឲ្យភាគីក៏ដូចជាអង្គជំនុំជម្រះអាចស្វែងរកដំណោះស្រាយដ៏ល្អ។ ដូចដែលខ្ញុំបាននិយាយរួចទៅហើយថា យើងមិនមែនព្យាយាមធ្វើការរាំងស្ទះដល់កិច្ចដំណើរការនីតិវិធី ឬក៏បញ្ឈប់មិនឲ្យមានការដំណើរការទៅមុខនោះឡើយ។

[១៣:៤៨:១៤]

កូនក្តីរបស់ខ្ញុំ បញ្ជាក់យ៉ាងច្បាស់ថា គាត់ចង់ឲ្យកិច្ចដំណើរការនីតិវិធីបន្តទៅមុខ។ បញ្ហាគឺថាតើយើងធ្វើដូចម្តេចដើម្បីការពារសិទ្ធិជាមូលដ្ឋានក្នុងការទទួលបានការជំនុំជម្រះប្រកបដោយយុត្តិធម៌។ លោក លោកស្រីចៅក្រម តាមរយៈការពិភាក្សាកាលពីម្សិលមិញដែលយើងបានធ្វើឡើង គឺហាក់ដូចជាមានការយល់ច្រឡំពីអង្គជំនុំជម្រះពាក់ព័ន្ធទៅនឹងអ្វីដែលបានបង្ហាញ ដាក់បង្ហាញជូនចំពោះយើងខ្ញុំ។ ដូច្នេះខ្ញុំគិតថាវាជាការចាំបាច់ដែលខ្ញុំត្រូវផ្តល់នូវទិដ្ឋភាពទូទៅនៃអ្វីដែលយើងបានទទួល រហូតមកដល់ថ្ងៃនេះ។

តាំងពីចុងឆ្នាំមុនម្ល៉េះ យើងបានទទួលនូវកំណត់ហេតុស្តាប់ចម្លើយសាក្សី និងដើមបណ្តឹងរដ្ឋប្បវេណី ដែលប្រគល់ឲ្យយើងដោយសហព្រះរាជអាជ្ញាអន្តរជាតិដែលមានការអនុញ្ញាតពីសហចៅក្រមស៊ើបអង្កេត។ ប៉ុន្តែដោយមិនមានការគាំទ្រពីសហព្រះរាជអាជ្ញាជាតិនោះឡើយ។ យើងបានទទួលនូវបណ្តុំនៃកំណត់ហេតុស្តាប់ចម្លើយនៅក្នុង ខែវិច្ឆិកា ឆ្នាំ២០១៤។ ឯកសារទាំងអស់នោះត្រូវបានបញ្ជូនឲ្យយើងបន្ថែមទៀតនៅចុងខែមករា។ ប៉ុន្តែយើងបានទទួលបន្ថែមទៀតប្រហែលជា ៨០ភាគរយនៃឯកសារទាំងអស់នៅក្នុងរយៈពេលពីរសប្តាហ៍ចុងក្រោយនេះ។ រួមបញ្ចូលទាំងឯកសារដែលត្រូវបានបញ្ជូនមកការិយាល័យ យើងទើបតែកាលពីម្សិលមិញពេលព្រឹកនៅពេលដែលពួកយើងកំពុងតែធ្វើដំណើរមកតុលាការនេះ។

[១៣:៤៩:៤០]

សហព្រះរាជអាជ្ញាអន្តរជាតិ កាលពីម្សិលមិញបានបង្ហាញថា ឯកសារដែលទទួលបានកាលពីម្សិលមិញ គឺគ្រាន់តែជាការបកប្រែទៅលើឯកសារដើមប៉ុណ្ណោះ។ ហើយប្រាកដហើយគឺគាត់និយាយនៅ -- គាត់ផ្តល់ព័ត៌មានត្រឹមត្រូវ។ ខ្ញុំមិនបានបញ្ជាក់ថាឯកសារទាំងអស់នេះ រួមបញ្ចូលទាំងការបកប្រែទៅជាភាសាអង់គ្លេសផងដែរ គឺជាភាសាដែលខ្ញុំនិងក្រុមគ្រួសារខ្ញុំអាចយល់ គឺជាភាសាដែលយើងប្រើប្រាស់នៅក្នុងក្រុមការងាររបស់យើង។

លោក លោកស្រីចៅក្រម! ទំហំដែលយើង -- ទំហំឯកសារហ្នឹង វាមានទំហំប៉ុនណាដែរ។ នៅចំណែកនេះយើងគណនា ហើយយើងទទួលបានកំណត់ហេតុស្តាប់ចម្លើយ១៥៥ ដែលមានចំនួនទំព័រសរុបគឺ ២៨៣៨ទំព័រ ជាភាសាអង់គ្លេសតែមួយប៉ុណ្ណោះ គឺម្ភៃ-- ២៨៣៨ គឺជិត៣០០០ទំព័រ។ ហើយសំខាន់ជាងនេះទៅទៀត ខាងព្រះរាជអាជ្ញាបានព្រមានដល់យើងថា ចំនួននៃឯកសារដែលត្រូវបង្ហាញនឹងកើនឡើងពីរដង ដោយសារតែហោចណាស់ក៏មានឯកសារប្រហែលជា១៩០ឯកសារទៀត ដែលត្រូវបញ្ជូនមក។ លើសពីនេះទៅទៀត គឺមានចំនួនឯកសារ ដែលយើងមិនដឹងថាមានចំនួនប៉ុន្មានទេដែលត្រូវបញ្ជូនមក ដោយសារតែសំណុំរឿង០០៣, ០០៤ កំពុងតែបន្តការស៊ើបអង្កេតនៅឡើយ។

[១៣:៥០:៥៦]

ដូចដែលលោក លោកស្រីចៅក្រមបានជ្រាបហើយថា អង្គជំនុំជម្រះបានផ្តល់ឱ្យយើងត្រឹមតែ ២ថ្ងៃ ដើម្បីសិក្សាអំពីកំណត់ហេតុស្តាប់ចម្លើយដែលយើងបានទទួលនៅក្នុងខែកុម្ភៈនេះ។ យើងបានគណនាថា យើងប្រហែលជាត្រូវអាននូវកំណត់ហេតុស្តាប់ចម្លើយជាភាសាអង់គ្លេសទាំងអស់ យ៉ាងហោចណាស់ក្នុងកម្រិតទាបបំផុតក៏មួយទំព័រក្នុងពេលមួយនាទី ក្នុងរយៈពេល២ថ្ងៃនេះ ដោយមិនបាច់សម្រាក មិនបាច់គេងអ្វីនោះទេ គឺគ្រាន់តែអានអ្វីៗទាំងអស់ ដែលយើងបានទទួល។ ដូច្នេះ យើងមិនទាំងគិតទៅដល់អង្គហេតុថា យើងត្រូវវិភាគនៅលើភស្តុតាងដែលមាននៅក្នុងឯកសារនោះទៀតផង។

លោក លោកស្រីចៅក្រម! ស្ថានភាពនេះ គឺជាស្ថានភាពដែលបង្កការព្រួយបារម្ភយ៉ាងខ្លាំងបំផុតចំពោះយើងខ្ញុំ។ ដោយមិនមានកំហុសអ្វីទាំងអស់នោះ យើងមើលឃើញថាសហព្រះរាជអាជ្ញាអន្តរជាតិ និង សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានទម្លាក់នូវឯកសារយ៉ាងធំនៅក្នុងសំណុំរឿង០០៣ និង ០០៤ មកលើបន្ទុករបស់យើងខ្ញុំ។ ខ្ញុំគិតថា ប្រហែលជាដើម្បីធានាថា ការព្យាយាមក្នុងការស៊ើបអង្កេតមិនៗឈានទៅដល់ការបរាជ័យនោះឡើយ ប្រសិនបើសំណុំរឿងមិនបានទទួលការជំនុំជម្រះ។ បន្ថែមពីលើ

នេះទៅទៀត អ្វីដែលបានបង្ហាញចំពោះយើង គឺជាចំណុចដ៏សំខាន់នៃបណ្តឹងសាទុក្ខរបស់យើងនៅក្នុងសំណុំរឿង០០២/០១ ដែលកំពុងតែស្ថិតនៅក្នុងការស៊ើបអង្កេតនៅក្នុងសំណុំរឿង០០៣ និង ០០៤ ហើយក្នុងពេលជាមួយគ្នានេះ ត្រូវបានជំនុំជម្រះនៅក្នុងអង្គជំនុំជម្រះសាលាដំបូង ហើយក៏កំពុងតែបន្តបណ្តឹងសាទុក្ខ។ ដើម្បីផ្តល់ទិដ្ឋភាពជាទូទៅនៃសំណុំរឿងទាំងអស់នេះ គឺយើងបានទទួលតាំងពីខែមករា គឺសាក្សីដែលបង្ហាញខ្លួននៅតុលាការ នៅពេលមួយខែក្រោយមក។

[១៣:៥២:៤០]

អ្នកស៊ើបអង្កេតបានសម្ភាសសាក្សីនៅក្នុងខែតុលា ឆ្នាំ២០១៤ ហើយក្នុងពេលនោះ គឺនៅពេលដែលអង្គជំនុំជម្រះបានធ្វើការរៀបចំកាលវិភាគ ដើម្បីស្តាប់សាក្សីនៅក្នុងតុលាការ។ ប្រសិនបើសវនាការមិនបានផ្អាករហូតទៅដល់ចុងខែមករាទេ ខ្ញុំគិតថា ប្រហែលជាយើងបានទទួលកំណត់ហេតុស្តាប់ចម្លើយ ហើយនិងភស្តុតាងដ៏សំខាន់ដែលមាននៅក្នុងឯកសារនោះ មុនពេលដែលសាក្សីមកបង្ហាញខ្លួននៅក្នុងតុលាការ។ ប៉ុន្តែវាមិនមែនត្រឹមតែអំពីទំហំនៃភស្តុតាងប៉ុណ្ណោះទេ ប៉ុន្តែវាៗទាំងខ្លួនឯងផ្ទាល់ គឺវាលើសអំពីធនធានដែលយើងមានស្រាប់ទៅទៀត។ ហើយខ្ញុំនឹងពិភាក្សានៅពេលបន្ទាប់ទៀតនេះ។

វាមានបញ្ហាសំខាន់មួយទៀតនៅទីនេះ ហើយគឺជាបញ្ហា -- ហើយព្រះរាជអាជ្ញាហាក់ដូចជាមិនយល់អំពីបញ្ហានេះឡើយ។ គឺថា វាមានភាពពាក់ព័ន្ធនៃភស្តុតាង នៅក្នុងកំណត់ហេតុស្តាប់ចម្លើយទាំងអស់នេះ។ តាម -- នេះ គឺជាមូលដ្ឋានរបស់យើង ដែលយើងគិតថា វាប៉ះពាល់ជាមូលដ្ឋានទៅដល់បញ្ហាថា តើនៅពេលណាដែលពួកយើងអាចពិនិត្យទៅលើភស្តុតាង ហើយថា តើនៅពេលណាដែលយើងអាចសួរដេញដោលសាក្សីអំពីភស្តុតាងទាំងអស់នោះ។ ផ្អែកទៅលើអ្វីដែលយើងអាចបានពិនិត្យពីភស្តុតាងទាំងអស់នោះ វាគឺមានភាពពាក់ព័ន្ធយ៉ាងខ្លាំងទៅនឹងសំណុំរឿងរបស់យើង គឺសំណុំរឿង០០២/០២ ទាំងស្រុងតែម្តង។ ហើយក៏ជាបញ្ហាមួយដែលយើងត្រូវប្រឈម។ ហើយឥឡូវនេះ យើងកំពុងតែធ្វើការប្តឹងសាទុក្ខនៅក្នុងសំណុំរឿង០០២/០១។ ភស្តុតាងមួយចំនួន គឺប៉ះពាល់ជាមូលដ្ឋានទៅលើភស្តុតាងអ្វីដែលយើងមាននៅក្នុងសំណុំរឿង អំពីបញ្ហាសំខាន់ៗជាច្រើន ដែលត្រូវបានជំទាស់នៅក្នុងសំណុំរឿងនេះ និងត្រូវបានជំទាស់នៅក្នុងបណ្តឹងសាទុក្ខ។

[១៣:៥៤:២៥]

លោក លោកស្រីចៅក្រម! ដើម្បីជៀសវាងការយល់ច្រឡំអំពីបញ្ហានេះ ខ្ញុំគិតថា វា -- ខ្ញុំចាំបាច់ត្រូវពន្យល់ ថាតើប្រធានបទអ្វីដែលត្រូវបានគ្របដណ្តប់នៅក្នុងភស្តុតាងនោះ។ ខ្ញុំនឹងមិនពិភាក្សាលម្អិត

ទៅលើបញ្ហាដែលមិនចាំបាច់នោះឡើយ។ តាមអ្វីដែលយើងបានអានកន្លងមកនុ៎ង គឺថាទី១ សាក្សីបាននិយាយអំពីអត្ថិភាពនៃការបែកបាក់ផ្ទៃក្នុងរបស់បក្សកុម្មុយនីស្តកម្ពុជា។ មានសក្ខីកម្មដែលថា មានបក្សផ្ទៃក្នុងចំនួនបួននៅក្នុងបក្សកុម្មុយនីស្តកម្ពុជា ទាំងអស់នោះគឺមានបក្សដែលត្រូវជាមួយនឹងវៀតមិញ ខ្មែរក្រហមជាតិនិយម ខ្មែរក្រហមសីហនុនិយម និងខ្មែរក្រហមមកចិន រួមទាំង ប៉ុល ពត ផង។ ព័ត៌មានអំពីបក្សនៅក្នុងចំណុចទាំងអស់នេះ គឺមាននៅក្នុងភូមិភាគពាយ័ព្យ និងភូមិភាគបូព៌ា ហើយក៏មានព័ត៌មានដែលកំណត់បង្ហាញថា សោ ភឹម គឺជាមេដឹកនាំមួយនៃបក្សមួយដែលធ្វើផែនការប្រឆាំងជាមួយនឹង ប៉ុល ពត។

សាក្សីក៏បានព័ត៌មានអំពីអំពើ និងការប្រព្រឹត្តរបស់មេដឹកនាំបក្សកុម្មុយនីស្តកម្ពុជាជាច្រើន រួមបញ្ចូលទាំងកូនក្តីរបស់ខ្ញុំគឺ នួន ជា ព្រមទាំង តាម៉ុក, សោម ភឹម និង រស់ ញឹម។ សាក្សីបានរៀបរាប់អំពីហេតុការណ៍ដែលត្រូវបានជំទាស់នៅក្នុងការជំនុំជម្រះទាំងស្រុងនៅក្នុងសំណុំរឿង០០២/០២ រួមទាំងហេតុការណ៍ដែលត្រូវបានជំនុំជម្រះរួចហើយនៅក្នុងសំណុំរឿង០០២/០១ ហើយឥឡូវនេះកំពុងតែស្ថិតក្នុងបណ្តឹងសាទុក្ខជាមួយនឹងអង្គជំនុំជម្រះតុលាការកំពូល។

[១៣:៥៦:១០]

សាក្សីក៏បានពិភាក្សាផងដែរ អំពីអំពើ និងការប្រព្រឹត្តរបស់សាក្សីដែលបានផ្តល់សក្ខីកម្មរួចមកហើយ ដែលត្រូវគ្រោងនឹងផ្តល់សក្ខីកម្ម ហើយដែលត្រូវបានស្នើសុំ ឬក៏ត្រូវបានកោះហៅឲ្យមកផ្តល់សក្ខីកម្ម។ សាក្សីក៏បានផ្តល់ព័ត៌មានលម្អិតអំពីរចនាសម្ព័ន្ធអាជ្ញាធរ ព្រមទាំងការប្រតិបត្តិនៅក្នុងភូមិភាគនិរតី និងភូមិភាគពាយ័ព្យ។ ហើយជាចុងក្រោយលោក លោកស្រីចៅក្រម សាក្សីបានផ្តល់ភស្តុតាងដែលទាក់ទងដោយផ្ទាល់ទៅនឹងអត្ថិភាពនៃគោលនយោបាយ រួមបញ្ចូលទាំងការរៀបការដោយបង្ខំ និងការប្រព្រឹត្តចំពោះជនជាតិចាម និងជនជាតិវៀតណាម។

ឥឡូវនេះគឺថា កាលពីម្សិលមិញព្រះរាជអាជ្ញាបានព្យាយាមច្រានចោលទឡ្ហីករណ៍របស់យើងដែលថាយើងមិនគួរស្តាប់សក្ខីកម្មរបស់កម្មាភិបាលថ្នាក់ដឹកនាំដែលត្រូវនឹងមកផ្តល់សក្ខីកម្មនោះឡើយ។ ហើយខ្ញុំគិតថា ពួកគេលើកទឡ្ហីករណ៍ទាំងអស់នេះដោយសារតែមានព័ត៌មានពាក់ព័ន្ធតែមួយប៉ុណ្ណោះដែលជាការយោងដោយផ្ទាល់ទៅនឹងកម្មាភិបាលមួយក្នុងចំណោមកម្មាភិបាលទាំងពីររូបនេះ។ ខ្ញុំក៏កត់សម្គាល់ឃើញផងដែរថា ជាទូទៅខាងព្រះរាជអាជ្ញាព្យាយាមសម្រេចចិត្ត ថាតើការជំនុំជម្រះមួយណា ឬក៏ឯកសារមួយណាដែលពាក់ព័ន្ធ ហើយបន្ទាប់មកព្យាយាមបង្ហាញនូវឯកសារនោះនៅមុនពេល ឬក៏

ក្នុងពេលនៃការជំនុំជម្រះទៅលើផ្នែកនោះ។

[១៣:៥៧:៣៥]

ក៏ប៉ុន្តែដោយសារមានការ -- ប៉ុន្តែដោយសារតែជាការងាររបស់យើង មិនមែនជាព្រះរាជអាជ្ញាដែលជាអ្នកដំណើរការរឿងក្តីនេះ គឺថាការវាយតម្លៃរបស់ព្រះរាជអាជ្ញាជាទូទៅគឺមិនត្រឹមត្រូវ ហើយមិនអាចជួយអ្វីបានទាំងអស់ រួមបញ្ចូលទាំងការវាយតម្លៃកាលពីម្សិលមិញរបស់ខាងព្រះរាជអាជ្ញា។ ដោយការច្រានចោលនូវភាពពាក់ព័ន្ធសំខាន់នៃសាក្សី ក៏ដូចជាភស្តុតាង ដោយសារតែសាក្សីនិងភស្តុតាងហ្នឹងមិនមានការនិយាយយោងផ្ទាល់។ ដូច្នេះខ្ញុំជឿជាក់ថា វាជាការមិនត្រឹមត្រូវ ហើយវាមិនមែនជាវិធីសាស្ត្រត្រឹមត្រូវក្នុងការវាយតម្លៃទៅលើភាពពាក់ព័ន្ធនៃភស្តុតាងនោះឡើយ។

ដូចដែលខ្ញុំបាននិយាយកាលពីម្សិលមិញ យើងជឿជាក់ថាកម្មាភិបាលដឹកនាំពីររូបនឹងអាចផ្តល់ព័ត៌មានដ៏សំខាន់បំផុតអំពីរចនាសម្ព័ន្ធអាជ្ញាធរ ក៏ដូចជាការប្រតិបត្តិនៅក្នុងភូមិភាគនិរតី។ ភស្តុតាងទាំងអស់នេះគឺជាការភ្ជាប់ទំនាក់ទំនងយ៉ាងសំខាន់ ដែលត្រូវបង្កើតឡើងរវាងភូមិភាគជាមួយនឹង នួន ជា ដើម្បីធ្វើការផ្តន្ទាទោស នួន ជា ពាក់ព័ន្ធទៅនឹងហេតុការណ៍ដែលកើតឡើងនៅត្រាំកក់ និងក្រាំងតាចាន់។

[១៣:៥៨:៤៥]

ដូចដែលខ្ញុំបាននិយាយកាលពីម្សិលមិញ ទោះបីថាយ៉ាងមិនទាន់អាចអានឯកសារទាំងអស់ត្រូវបានបង្ហាញ ដែលយើងបានទទួលក្នុងរយៈពេលពីរសប្តាហ៍កន្លងមកក៏ដោយ ក៏យើងអាចកំណត់បានថាឯកសារទាំងនោះភាគច្រើនគឺបង្ហាញពីរចនាសម្ព័ន្ធអាជ្ញាធរនៅក្នុងត្រាំកក់ និងនៅក្រាំងតាចាន់។ ដូចដែលខ្ញុំនិយាយកាលពីម្សិលមិញ គឺពាក្យថា “តំបន់១៣, ស្រុកត្រាំកក់ ឬក៏មន្ទីរ២០៤” ត្រូវបានលើកឡើងមកបង្ហាញ សរុបទាំងអស់គឺ៣២៤ដង។

នៅពេលដែលយើងពិនិត្យមើលទៅលើឯកសារដែលបានបង្ហាញទាំងអស់នេះឲ្យបានលម្អិត គឺយើងឃើញថា ឯកសារទាំងអស់នោះហាក់ដូចជាមានព័ត៌មានដែលមានភាពពាក់ព័ន្ធយ៉ាងសំខាន់ទៅលើចំណុចជាច្រើននៃសំណុំរឿងរបស់មេធាវីការពារក្តី មិនមែនត្រឹមតែសាក្សីជាក់លាក់ ឬក៏ហេតុការណ៍ជាក់លាក់ដែលយើងត្រូវធ្វើការពិនិត្យនៅក្នុងផ្នែកនៃការជំនុំជម្រះជាក់លាក់ណាមួយនោះឡើយ។ ភស្តុតាងទាំងអស់នេះតម្រូវឲ្យមានការវិភាគបន្ថែមទៀត មុនពេលដែលផ្នែកនៃការជំនុំជម្រះបច្ចុប្បន្នហ្នឹងអាចបន្តទៅមុខបាន។ និយាយឲ្យត្រង់ទៅគឺថា វាគឺជាសិទ្ធិរបស់ជនជាប់ចោទ ដើម្បីមានពេលវេលាក្នុងការពិនិត្យទៅលើភស្តុតាងទាំងអស់នេះ ហើយពិចារណាថាតើវាប៉ះពាល់យ៉ាងណា ដោយមិនមែន

ត្រឹមតែពិចារណាទៅលើហេតុការណ៍ ដែលបានជំទាស់នៅក្នុងផ្នែកនៃការជំនុំជម្រះបច្ចុប្បន្ននោះទេ ប៉ុន្តែថាតើវាប៉ះពាល់យ៉ាងណាទៅដល់យុទ្ធសាស្ត្រក្នុងការការពារក្តីទាំងមូលតែម្តង។ វាច្បាស់ណាស់ថា យុទ្ធសាស្ត្រជារួមរបស់យើងបានប្រាប់យើងអំពីវិធីសាស្ត្រដែលយើងត្រូវធ្វើសម្រាប់ផ្នែកនៃការជំនុំជម្រះនីមួយៗ និងសាក្សី ក៏ដូចជាដើមបណ្តឹងរដ្ឋប្បវេណី ឬក៏អ្នកជំនាញទាំងអស់ដែលយើងត្រូវកោះហៅមកផ្តល់សក្ខីកម្មនៅក្នុងផ្នែកនីមួយៗ។ ប្រសិនបើយើងជំរុញទៅមុខដោយមិនគិតអ្វីទាំងអស់ ដែលយើងគិតតែការជំនុំជម្រះ ហើយទទួលបាននូវភស្តុតាង ដូច្នេះវានឹងបង្កើតឲ្យមានការលំបាកកាន់តែខ្លាំងសម្រាប់ពួកយើង ក៏ដូចជាការជំនុំជម្រះ។ ឥឡូវនេះ វាបានកើតឡើងរួចទៅហើយ។ ឧទាហរណ៍អំពីអ្វីដែលយើងបានឃើញនៅក្នុងចម្លើយដែលបានផ្តល់មកយើងនៅក្នុងសប្តាហ៍ -- ពីរសប្តាហ៍កន្លងមកនោះយើង -- ប្រសិនបើយើងបានជួប ប្រហែលជាយើងសួរសំណួរផ្សេងៗពីនេះទៅ អេលីហ្សេបេត បេកយ័រ ហើយប្រហែលជាសួរសំណួរផ្សេងពីនេះទៅអ្នកជាប់គុកនៅក្រាំងតាចាន់ ព្រមទាំងកម្មាភិបាលដែលបានមកបង្ហាញខ្លួននៅទីនេះ។

[១៤:០១:១៧]

ឥឡូវនេះ យើងត្រូវតែធ្វើសំណើដើម្បីឲ្យកោះហៅសាក្សីនិងអ្នកជំនាញទាំងអស់នេះមកវិញ។ ខ្ញុំគិតថា ហេតុការណ៍នេះវានឹងបង្កឲ្យមានការពន្យារពេលសវនាការ ហើយធ្វើឲ្យប៉ះពាល់ដល់ការប្រើប្រាស់ធនធានដែលមានកំណត់របស់តុលាការ។ ប៉ុន្តែ យើងចាំបាច់ត្រូវតែលើកឡើងនូវបញ្ហាទាំងអស់នេះជូនទៅអង្គជំនុំជម្រះតុលាការកំពូល ដោយសារតែយើងគិតថាវាក៏ប៉ះពាល់ ហើយក៏មានភាពពាក់ព័ន្ធផងដែរទៅនឹងបណ្តឹងសាទុក្ខនៅក្នុងសំណុំរឿង០០២។ ទាំងអស់នេះ វានឹងធ្វើឲ្យមានការប៉ះពាល់ ធ្វើឲ្យមានភាពស្មុគស្មាញ និងធ្វើឲ្យពន្យារនូវកិច្ចដំណើរការនីតិវិធីបណ្តឹងសាទុក្ខ។ ហើយជាពិសេសចំពោះសវនាការបណ្តឹងសាទុក្ខដែលនឹងធ្វើនៅពេលខាងមុខនេះ។

ចំពោះសំអាងហេតុទាំងអស់នេះហើយ ទើបយើងស្នើសុំឲ្យមានការផ្អាកសវនាការក្នុងពេល -- ចាប់ពីពេលឥឡូវនេះ។ ហើយប្រហែលជា ឬក៏មួយទៀត គឺថាយើងបញ្ចប់ផ្នែកនេះ ដោយស្តាប់សាក្សីទាំងអស់ លើកលែងតែកម្មាភិបាលដឹកនាំបន្ថែម។ លើសពីនេះទៅទៀត យើងសូមស្នើសុំថា ប្រសិនបើយើងចាប់ផ្តើម ឬក៏នៅពេលដែលយើងចាប់ផ្តើមសវនាការលើផ្នែកបន្ទាប់ យើងសូម -- យើងស្នើសុំធ្វើការជ្រើសរើសផ្នែកដែលគិត -- ដែលយើងគិតថាវាអាចប៉ះពាល់តិចបំផុតចំពោះការបង្ហាញឯកសារដែលកំពុងតែធ្វើនេះ។ ដូច្នេះ គឺមិនប៉ះពាល់ទៅលើខាងនិរតី និងខាងពាយ័ព្យ។ ខ្ញុំគិតថាប្រហែលជា

ផ្នែកដែលពាក់ព័ន្ធទៅលើទំនប់១មករា។

[១៤:០២:៤០]

ក្រៅពីចំណុចទាំងអស់នេះ យើងត្រូវការពេលវេលាគ្រប់គ្រាន់ដើម្បីពិនិត្យមើលទៅលើកំណត់ហេតុស្តាប់ចម្លើយដែលបានបង្ហាញ ដែលបានប្រគល់មកយើង មុនពេលដែលយើងអាចចាប់ផ្ដើមដំណើរការទៅលើសវនាការ។

ឥឡូវនេះ ខ្ញុំសូមងាកត្រឡប់ទៅលើចំណុចសំខាន់មួយទៀត ដែលយើងមិនបានពិភាក្សាកាលពីម្សិលមិញទាល់តែសោះ។ ទាំងអស់នោះគឺអំពីភស្តុតាងទាក់ទងទៅនឹងខ្មែរក្រោម។ ឥឡូវនេះ ខ្ញុំចង់លើកឡើងឲ្យអង្គជំនុំជម្រះជ្រាបអំពីប្រធានបទមួយ គឺប្រធានបទដែលយើងគិតថាវាពាក់ព័ន្ធយ៉ាងខ្លាំងផងដែរនៅក្នុងសំណុំរឿង០០៣, ០០៤ គឺទាក់ទងទៅនឹងការទទួលរងគ្រោះរបស់ខ្មែរក្រោមនៅក្នុងរបបខ្មែរ-ក្រហម។ កាលពីសវនាការកន្លងនៅក្នុងខែនេះ យើងបានបង្ហាញរួចទៅហើយនូវការព្រួយបារម្ភរបស់យើងអំពីភាពពាក់ព័ន្ធនៃភស្តុតាងខ្មែរក្រោមសម្រាប់សំណុំរឿង០០២/០២។

ដូចដែរយើងបានដឹងទាំងអស់គ្នាថា ភាពពាក់ព័ន្ធនៃបទពិសោធន៍ខ្មែរក្រហមទទួលរងនៅក្នុងសំណុំរឿង០០២ ត្រូវបានជំទាស់តាំងពីយូរណាស់មកហើយ។ សហគមន៍ខ្មែរក្រហមបានទទូចសុំឲ្យមានការជំនុំជម្រះអំពីបទពិសោធន៍របស់ពួកគាត់នៅក្នុងបរិបទនៃសំណុំរឿង០០២ ក្នុងបទមនុស្ស -- ប្រល័យពូជសាសន៍និងការប្រព្រឹត្តមិនត្រឹមត្រូវទៅលើក្រុមជាក់លាក់។ ហើយការព្យាយាមទាំងអស់នោះត្រូវបានលើកឡើងនៅក្នុងប្រព័ន្ធផ្សព្វផ្សាយ ក៏ដូចជាឯកសារនៅក្នុងសំណុំរឿងរបស់យើង។ ក៏ប៉ុន្តែនៅពេលដែលយើងត្រឡប់ទៅពេលចាប់ផ្ដើមសំណុំរឿង០០២ សហព្រះរាជអាជ្ញាសម្រេចចិត្តថា មិនដាក់បញ្ចូលខ្មែរក្រហមធ្វើជាក្រុមជាក់លាក់មួយនៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ។

[១៤:០៤:២៨]

ទោះបីជាមានការទទូចអង្វរសុំយ៉ាងណាក៏ដោយ ក៏ពួកគេមិនបានដាក់នូវដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែម។ ប៉ុន្តែ ពួកគេគ្រាន់តែដាក់នូវសំណើដែលមានកម្រិតកំណត់ឲ្យមានការស៊ើប -- ឲ្យមានការបំពេញកិច្ចស៊ើបសួរតែប៉ុណ្ណោះ។ ដូចដែលលោក លោកស្រីចៅក្រម អាចពិនិត្យឃើញយ៉ាងច្បាស់នៅក្នុងសារណារបស់ខ្ញុំ នៅពេលនោះអ្នកនាំពាក្យ អ.វ.ត.ក គឺលោក ឡាស អលសិន បានប្រាប់សារព័ត៌មានខេមបូឌាដេលីថា គឺនៅក្នុងឆ្នាំ២០១០ថា ការណ៍ដែលព្រះរាជអាជ្ញាមិនបានដាក់នូវដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមនោះ គឺមិនមែនជាកំហុសនោះឡើយ។ ខ្ញុំសូមបញ្ជាក់។ នៅពេល

ដែលគាត់និយាយនេះ គឺខ្ញុំសូមដកស្រង់ “គឺថាមានហេតុផលដែលពួកគេមិនធ្វើដូច្នេះ ខ្ញុំដឹងហេតុផល ប៉ុន្តែខ្ញុំមិនអាចប្រាប់អស់លោកបានទេអំពីហេតុផល”។ ប្រហែលជាយើងអាចទទួលបានហេតុផលនៅថ្ងៃនេះក៏មិនដឹង ខ្ញុំមិនច្បាស់។

ដោយសារតែព្រះរាជអាជ្ញាមិនបានដាក់បញ្ចូលក្រុមខ្មែរក្រោមទៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ ឬក៏ដីកាសន្និដ្ឋានបញ្ជូនឲ្យស៊ើបសួរបន្ថែម លទ្ធផលគឺថាខ្មែរក្រហមមិនត្រូវបានកំណត់ថាជាក្រុមគោលដៅនៅក្នុងដីកាដំណោះស្រាយឡើយ ឬក៏មិនត្រូវបានកំណត់ថាជាជនរងគ្រោះនៃអំពើប្រល័យពូជសាសន៍នោះឡើយ។ មានការនិយាយតិចតួចបំផុតអំពីខ្មែរក្រោមនៅក្នុងដីកាដំណោះស្រាយ។

[១៤:០៥:៥៤]

លោក លោកស្រីចៅក្រម! ដោយសារតែខ្មែរក្រោមមិនមែនជាក្រុមគោលដៅនៅក្នុងសំណុំរឿង ០០២ ដូច្នេះហើយការផ្តោតទៅលើបទពិសោធន៍របស់ខ្មែរក្រហមនៅក្នុងកំណត់ហេតុស្តាប់ចម្លើយដែលយើងបានទទួលសំណុំរឿង០០៣ និង ០០៤ គឺបង្កឲ្យមានបញ្ហាយ៉ាងខ្លាំងដល់យើងខ្ញុំ។ ជាពិសេសយើងព្រួយបារម្ភកាន់តែខ្លាំងឡើងៗ ដែលថាព្រះរាជអាជ្ញាអន្តរជាតិមានចេតនាពង្រីកទៅលើវិសាលភាពនៃសំណុំរឿង០០២/០២ ដោយធ្វើការជំនុំជម្រះទៅលើបទពិសោធន៍របស់ខ្មែរក្រហមដែលយើងចាត់ទុកថាក្រុមគោលដៅ និងជាក្រុម និងជាជនរងគ្រោះនៃអំពើប្រល័យពូជសាសន៍។

អ្វីដែលយើងព្រួយបារម្ភ គឺថាព្រះរាជអាជ្ញាកំពុងតែព្យាយាមធ្វើដូច្នេះដោយការដាក់បញ្ចូលខ្មែរក្រោមតាមទ្វារក្រោយ។ ដោយការបញ្ចូលបទពិសោធន៍របស់ខ្មែរក្រោម បញ្ចូលជាមួយជនជាតិវៀត-ណាម ទោះបីថាវាមានលក្ខណៈខុសគ្នាដាច់ដោយឡែករបស់ក្រុមទាំងពីរ ព្រមទាំងបទពិសោធន៍របស់ខ្មែរក្រហមដែលមិនត្រូវបានចោទប្រកាន់ជាក់លាក់នៅក្នុងដីកាដំណោះស្រាយក៏ដោយ។

[១៤:០៦:៥៩]

ប្រាកដណាស់ថាវាបង្ហាញថា អត្តសញ្ញាណជាក់លាក់របស់សាក្សីក្នុងនាមជាខ្មែរក្រោម គឺមានពាក់ព័ន្ធតិចតួចបំផុតចំពោះព្រះរាជអាជ្ញា ចំពោះមេធាវីដើមបណ្តឹងរដ្ឋប្បវេណី ក៏ដូចជាអង្គជំនុំជម្រះនេះដែរ។ តាមពិតទៅ លោក លោកស្រីអាចចាំផងដែរថា ទោះបីជាសាក្សីមានសាក្សីម្នាក់ដែលបានមកផ្តល់សក្ខីកម្មនៅក្នុងពេលថ្មីៗនេះ បានសង្កត់ធ្ងន់ថាគាត់មិនមែនជាខ្មែរក្រោម ហើយគាត់ក៏មិនដែលនិយាយថាគាត់ជាខ្មែរក្រោមក៏ដោយ ក៏ចៅក្រម ឡាវែន៍ នៅតែបន្តសួរសាក្សី ថាតើសាក្សីហ្នឹងគាត់ចាត់ទុកថាខ្លួនគាត់ជាខ្មែរក្រោម ឬក៏មិនមែន។

លោក លោកស្រីចៅក្រម! ដោយសារតែមានការផ្តោតទៅលើបទពិសោធរបស់ខ្មែរក្រហម ហើយដោយសារតែកំណត់ត្រាកន្លងមករបស់ព្រះរាជអាជ្ញាទាក់ទងទៅនឹងបញ្ហាខ្មែរក្រោម ទើបយើងស្នើសុំនៅក្នុងញត្តិរបស់យើង ដែលថាអង្គជំនុំជម្រះធានាដល់ភាគីថាខ្មែរក្រោមហ្នឹង នឹងមិនត្រូវបានបញ្ចូលទៅជាគោល ក្រុមគោលដៅនៅក្នុងសំណុំរឿង០០២/០២ នោះឡើយ។

[១៤:០៨:១៤]

អ្វីដែលខ្ញុំចង់បន្តទៅទៀតនេះ គឺអំពីស្ថានភាពគតិយុត្តិនៃកំណត់ហេតុស្តាប់ចម្លើយដែលបានបញ្ចូលពីសំណុំរឿង០០៣ និង ០០៤។ យើងមានការព្រួយបារម្ភអំពីស្ថានភាពផ្លូវច្បាប់ យើងព្រួយបារម្ភអំពីមាន អំពីអ្វីដែលថាសំណុំរឿង០០៣ និង ០០៤ មិនអាចឃើញពន្លឺនៃការជំនុំជម្រះ។ ឥឡូវនេះគឺថាមានការចោទប្រកាន់ដោយកំបាំងមុខ ហើយក្នុងពេលថ្មីៗនេះសម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន បាននិយាយប្រាប់ហើយថា រដ្ឋាភិបាលកម្ពុជាបាននិយាយថា វាមានលទ្ធភាពដែលថាសំណុំរឿង០០២ គឺជាសំណុំរឿងចុងក្រោយ។ ប្រសិនបើសំណុំរឿង០០៣ និង០០៤ មិនអាចទទួលបានការជំនុំជម្រះ យើងមិនដឹងថាមានផលប៉ះពាល់អ្វីដែលមានទៅលើសុពលភាពនៃកំណត់ហេតុស្តាប់ចម្លើយនោះឡើយ។ យើងមិនដឹងថា តើការណ៍ទាំងអស់នេះនឹងប៉ះពាល់ដល់សំណុំរឿង០០២/០០២ ដោយរបៀបណា និងថាតើស្ថានភាពនឹងត្រូវចាត់ចែងដោយរបៀបណា។ ឧទាហរណ៍បន្ទាប់ពីព្យាយាមធ្វើការខិតខំប្រឹងប្រែងគ្រប់បែបយ៉ាងដើម្បីអានកំណត់ហេតុស្តាប់ចម្លើយ ថាតើវាអាចដែរឬទេ ដែលយើងត្រូវបានគេប្រាប់នៅពេលចុងក្រោយមកថា យើងដកស្រង់ ហើយយើងចាំបាច់ត្រូវតែលុបការណ៍ដែលយើងទើបតែអានចេញពីក្នុងខួរក្បាលយើងវិញបាននោះ។

ដូច្នេះខ្ញុំគិតថា វាតិតបំផុត វាត្រូវការឲ្យមានការពិចារណា ថាតើយើងធ្វើការគ្រប់គ្រងទៅលើដំណើរការនៃការបង្ហាញឯកសារនេះដោយរបៀបណា។

ចំណុចមួយទៀតដែលខ្ញុំចង់លើកបង្ហាញផងដែរ គឺថាយើងការព្រួយបារម្ភអំពីសំណុំរឿង០០៣ និង ០០៤ ដែលមានព័ត៌មានពាក់ព័ន្ធផងដែរ បន្ថែមពីលើកំណត់ហេតុស្តាប់ចម្លើយសាក្សីដើម្បណ្តឹងរដ្ឋប្បវេណី។ ឧទាហរណ៍ដូចជាឯកសារនានា ដែលមាន។ និយាយតាមពិតទៅ ខ្ញុំគ្មានអ្វីពាក់ព័ន្ធជាមួយសហចៅក្រមស៊ើបអង្កេតអន្តរជាតិនៅក្នុងសំណុំរឿង០៣ និង០៤ នោះឡើយ ហើយខ្ញុំគិតថាគាត់ក៏មិនមានអ្វីពាក់ព័ន្ធជាមួយនៅក្នុងអង្គជំនុំជម្រះនេះដែរ។ ហេតុនេះហើយ ទើបយើងត្រូវស្នើសុំឲ្យអង្គជំនុំជម្រះដើម្បីបង្គាប់ឲ្យដល់សហចៅក្រម -- សហព្រះរាជអាជ្ញាឲ្យជម្រាបមកយើង ថាតើវាមានប្រភេទ

នៃភស្តុតាងដទៃទៀតឬក៏អត់ ប្រសិនបើដូច្នេះ យើងស្នើសុំដល់អង្គជំនុំជម្រះដើម្បីបង្គាប់ដល់ព្រះរាជអាជ្ញាដើម្បីស្នើសុំឲ្យមានការបង្ហាញនូវភស្តុតាងនេះ ឲ្យបានឆាប់រហ័សតាមដែលអាចធ្វើទៅបាន។

[១៤:១០:៥១]

ឥឡូវនេះ យើងនិយាយអំពីស្ថានភាពនៃការបង្ហាញឯកសារ ខ្ញុំបាននិយាយពីម្សិលមិញរួចទៅហើយ។ នៅក្នុងសារណារបស់យើង យើងបានស្នើសុំឲ្យអង្គជំនុំជម្រះឲ្យប្រើប្រាស់ឆន្ទានុសិទ្ធិក្នុងការរក្សាសណ្តាប់ធ្នាប់ឲ្យបានល្អនៅក្នុងសវនាការ ដោយការលុបបំបាត់ចោលស្ថានភាពបង្ហាញដែលមិនច្បាស់លាស់។ ហើយស្ថានភាពទាំងអស់នោះ ត្រូវបានបង្ហាញកាលពីម្សិលមិញដោយសង្ខេប គឺថាយើងមិនបានទទួលកំណត់ហេតុស្តាប់ចម្លើយជាបែបអេឡិចត្រូនិកឡើយ។ យើងទទួលបានត្រឹមតែជាឯកសារក្រដាសតែមួយភាសាប៉ុណ្ណោះ។ មានតែបុគ្គលិកដែលទទួល បុគ្គលិកពេញម៉ោងរបស់យើងប៉ុណ្ណោះដែលអាចពិនិត្យមើលទៅលើកំណត់ហេតុស្តាប់ចម្លើយ មិនមែនទៅលើ -- ហើយកម្មសិក្សាការីមិនអាចមើលនោះឡើយ ទោះបីខ្ញុំដឹងថា សហកម្មសិក្សាការីរបស់ព្រះរាជអាជ្ញាអាចធ្វើក៏ដោយ។ ចំពោះកំណត់ហេតុដែលអាចស្រាវជ្រាវតាមពាក្យ ឬក៏ដែលអាចពិនិត្យបានទាំងអស់គ្នានេះ យើងត្រូវតែស្កេន បន្ទាប់មកព្រីន ហើយបន្ទាប់មក យើងត្រូវដំណើរការមួយដែលយើងហៅថា ការទទួលស្គាល់អត្ថបទតាមបែបអេឡិចត្រូនិក។ ដូច្នេះ ដោយសារតែវាមានទំហំ ហើយបច្ចេកវិទ្យាមានការលំបាក ដូច្នេះ ខ្ញុំគិតថាគឺនេះជាដំណើរការដែលចំណាយពេលវេលាយ៉ាងខ្លាំង។ ខ្ញុំគិតថា ទាំងអស់នេះ វាប៉ះពាល់ទៅដល់សំណុំរឿង០០៤ ហើយខ្ញុំជឿជាក់ផងដែរ វាមិនពាក់ព័ន្ធនៅពេលនេះទេ ដោយសារថាសហចៅក្រមស៊ើបអង្កេតបានដាក់ចោទទៅលើជនជាប់ចោទពីររូប នៅក្នុងសំណុំរឿង០០៣, ០០៤ គួរតែដកចេញនៅពេលនេះ។

[១៤:១២:២៥]

ជាចុងក្រោយគឺថាចំណុចដែលខ្ញុំចង់និយាយ គឺអំពីការលំបាកផ្នែកពេលវេលា និងធនធានរបស់មេធាវីការពារក្តី។ ខ្ញុំចង់និយាយដោយខ្លីអំពីបញ្ហាលំបាកដែលយើងជួបប្រទះ។ ដូចដែលខ្ញុំបានបញ្ជាក់រួចទៅហើយ ថាយើងទទួលបានកំណត់ហេតុស្តាប់ចម្លើយជាង៨០ភាគរយក្នុងរយៈពេលត្រឹមតែពីរសប្តាហ៍កន្លងមកនេះ។ ហើយសូម្បីតែម្សិលមិញក៏យើងបានទទួល ប៉ុន្តែនៅក្នុងពេលទាំងអស់នេះ យើងអាចឃើញថាសមាជិកក្រុមការពារក្តីទាំងអស់គឺនៅក្នុងសវនាការនេះអស់រយៈពេល៤ថ្ងៃក្នុង១សប្តាហ៍។ ការនេះ គឺដោយសារតែយើងមានធនធានកម្រិតទាក់ទងទៅនឹងទំហំនៃក្រុមការងាររបស់យើង។ ដូចដែល

ខ្ញុំបង្ហាញកាលពីម្សិលមិញ ខាងព្រះរាជអាជ្ញា គឺមានព្រះរាជអាជ្ញាអន្តរជាតិយ៉ាងតិចក៏ប្រាំមួយរូបដែលធ្វើការដឹកនាំក្នុងការពិនិត្យ ហើយបានបែងចែកការងាររបស់បុគ្គលិកគាំទ្រ។ ប៉ុន្តែយើងមានត្រឹមតែមេធាវីពីររូបប៉ុណ្ណោះ។ បន្ថែមលើនេះ យើងត្រូវមានពេលវេលាបន្ថែម១ថ្ងៃក្នុង១សប្តាហ៍ ហើយនិងពេលល្ងាច ហើយនិងចុងសប្តាហ៍ដើម្បីពិនិត្យមើលឯកសារដ៏រាប់ពាន់ទំព័រ។ យើងមានត្រឹមតែពេល១ថ្ងៃក្នុង១សប្តាហ៍ ដើម្បីពិភាក្សាទៅលើភស្តុតាងដ៏ខ្លាំងដែលយើងបាន -- អំពីឯកសារដែលបានផ្តល់ហ្នឹងជាមួយនឹង នួន ជា ហើយនិងស្នើសុំការណែនាំពីគាត់តែប៉ុណ្ណោះ។

លោក លោកស្រីចៅក្រម យើងធ្វើការងារទាំងអស់នេះ រួមជាមួយនឹងការរៀបចំសវនាការជារៀងរាល់ថ្ងៃ។ យើងត្រូវតែធ្វើដោយមិនមានការគាំទ្រពីកម្មសិក្សាការីរបស់មេធាវីការពារក្តី។ ហើយក្នុងពេលជាមួយគ្នានេះ យើងហាក់ដូចជាធ្វើការងារក្នុងពេលដែលព្រះរាជអាជ្ញាគិតតែទម្លាក់ឯកសារមកយើង។

[១៤:១៣:៥៩]

យើងបានព្យាយាមក្នុងសំណុំរឿង០០២ ដើម្បីឲ្យបានយល់អំពីសំណុំរឿង ហើយយើងព្យាយាមអានឯកសារទាំងអស់នោះ ទោះបីជានៅក្នុងសាលសវនាការពេញថ្ងៃក្នុងរយៈពេល៤ថ្ងៃក្នុង១សប្តាហ៍ក៏ដោយ ប៉ុន្តែយ៉ាងណាក៏ដោយ គឺវាមិនអាចធ្វើទៅរួចនោះទេ។ យើងមិនអាចអាន កុំថាដល់ទៅធ្វើការវិភាគឲ្យលម្អិតទៅលើកំណត់ហេតុស្តាប់ចម្លើយដែលបានបង្ហាញមកយើងទាំងអស់។ ទាំងអស់នេះគឺថាវាពិតជាមិនអាចធ្វើទៅបាន ទោះបីថាព្រះរាជអាជ្ញាគាត់បានស្នើសុំ ឬក៏គាត់បានលើកជាសំណើច្រើនក៏ដោយ។ យើងមិនមានធនធាន ឬក៏មិនមានពេលវេលា ហើយធនធានពេលវេលាយើងមាន គឺយើងត្រូវចំណាយពេលដោយអត់ប្រយោជន៍ដើម្បីការបង្ហាញដំណើរការទាំងអស់នេះ។

ខ្ញុំសូមបញ្ចប់ការសន្និដ្ឋានរបស់ខ្ញុំ ហើយខ្ញុំគិតថា យើងមិនអាចបន្តបែបនេះទេ ប្រសិនបើដំណើរការបង្ហាញឯកសារនៅតែបន្តនៅក្នុងលក្ខណៈដូចគ្នានេះ ហើយខ្ញុំគិតថាវានឹងប្រហែលជាបន្តទៅទៀតនោះ។ ខ្ញុំចាំបាច់ត្រូវតែធ្វើសំណើសុំឲ្យមានការបន្ថែមធនធានដើម្បីដោះស្រាយទៅលើបញ្ហា។ ប៉ុន្តែប្រសិនបើទោះបីជាសំណើនោះត្រូវបានទទួលការឯកភាពក៏ដោយ ក៏យើងត្រូវការពេលវេលាដើម្បីឲ្យសមាជិកក្រុមការងាររបស់យើងមានឱកាសយល់អំពីខ្លឹមសារនៃឯកសារដែលបានបញ្ចេញនេះ។ នេះគឺជាការទទួលខុសត្រូវផ្នែកវិជ្ជាជីវៈរបស់យើងក្នុងនាមជាមេធាវី ដែលតម្រូវឲ្យយើងត្រូវតែធ្វើដូច្នេះ។

ឥឡូវនេះយើងស្នើសុំឲ្យមានការសង្កត់ធ្ងន់ទៅលើការអានឯកសារថ្មីក្នុងរយៈពេលកន្លងមកនេះ

នៅពេលដែលព្រះរាជអាជ្ញា គឺគាត់ចាប់ផ្ដើម ប្រហែលតាំងពីប៉ុន្មានខែមុនមកយើងម្ល៉េះ។ តាមពិតទៅកំណត់ហេតុស្ដាប់ចម្លើយមួយចំនួនត្រូវបានចាត់ទុកថាជាកំណត់ហេតុចាស់ គឺថាតាំងពីឆ្នាំ២០១១។ ដូច្នេះហើយគឺថាខាងព្រះរាជអាជ្ញាគាត់មានពេលវេលាមុនយើងយ៉ាងច្រើន។ ច្បាស់ណាស់ថាយើងមិនសង្ឃឹមថាយើងអាចទទួលពេលវេលាដូចគ្នានោះទេ ដោយសារតែយើងគិតអំពីភាពឆាប់រហ័សនៃសវនាការ។ ប៉ុន្តែយ៉ាងណាក៏ដោយ យើងត្រូវការពេលវេលា។ សូមអរគុណ។

[១៤:១៦:០៥]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ លោក វ៉ិចទ័រ កូប៉េ។

បាទ ឥឡូវនេះអង្គជំនុំជម្រះផ្ដល់វេទិកាជូនទៅក្រុមមេធាវីការពារក្ដីលោក ខៀវ សំផន។

**លោក គង់ សំអុន៖**

បាទ សូមអរគុណលោកប្រធាន។ សូមគោរពអង្គជំនុំជម្រះ អង្គប្រជុំទាំងអស់។ យើងខ្ញុំមានបញ្ហាមិនខុសគ្នាពីក្រុមមេធាវីរបស់លោក នួន ជា ទេ។ ការលំបាករបស់យើង គឺពិតជាមានច្រើននៅក្នុងការពិនិត្យទៅលើឯកសារទាំងអស់នេះ។ ដោយសារថាការជូនដំណឹងរបស់សហព្រះរាជអាជ្ញាស្ដីអំពីសេចក្ដីថ្លែងការណ៍ដែលបានទទួលនេះ គឺក្នុងក្របខ័ណ្ឌមួយនៃការស៊ើបអង្កេតនៃសំណុំរឿង០០៣, ០០៤ ហើយនៅពេលនេះ យើងមិនមានពេល និងមិនមានមធ្យោបាយគ្រប់គ្រាន់ដែលត្រូវបានបង្កឲ្យមានភាពងាយស្រួល ចាំបាច់ក្នុងការរៀបចំការពារក្ដីឲ្យកូនក្ដីរបស់យើងនោះទេ។ តែថាយើងខ្ញុំត្រូវការពេលវេលាដើម្បីពិនិត្យភស្ដុតាង ដែលដាក់ដោយសហព្រះរាជអាជ្ញា។

[១៤:១៧:២៥]

ទី១ ទាក់ទងទៅនឹងឯកសារនេះ យើងឃើញថាជាចំនួនច្រើនដែលរហូតមកដល់ពេលនេះ យើងទទួលបានចំនួន១៦ក្រុណ្ឌធំ ដូចលោកមេធាវី កូប៉េ បានបង្ហាញហើយថាមានជិត៣.០០០ទំព័រឯណោះ។ ហើយឯកសារទាំងអស់នោះ វាមានលក្ខណៈខុសៗគ្នា ដែលត្រូវឲ្យយើងធ្វើការពិនិត្យទៅលើភាពពាក់ព័ន្ធទៅនឹងឯកសារនោះផងដែរ។ ម្យ៉ាងទៀតយើងឃើញថា ទាក់ទងទៅនឹងការបកប្រែភាសានៃឯកសារទាំងអស់នេះ ក៏មានការលំបាក មានការប្រឈមផងដែរ ដោយសារការផ្ដល់ឲ្យនូវឯកសារនេះ។ ជួនកាលឯកសារនេះមានភាសាខ្មែរ អត់ភាសាបារាំង មានភាសាបារាំង អត់ភាសាអង់គ្លេសជាដើម អ៊ីចឹងទៅ ហើយដែលត្រូវឲ្យមានការរង់ចាំទៅលើការពិនិត្យទៅលើឯកសារទាំងអស់នេះ គឺរង់ចាំការ

បកប្រែហ្នឹងទៀតផង។

សម្រាប់ឯកសារដ៏ច្រើនបែបនេះយើងមិនមែនថាត្រូវចំណាយពេលដែលអានប៉ុណ្ណោះទេ គឺយើងត្រូវការពេលវេលាសម្រាប់ធ្វើការវិភាគទៅលើបញ្ហានៃឯកសារ បញ្ហាដែលមាននៅក្នុងឯកសារដែលជាប់ពាក់ព័ន្ធគ្នាពីឯកសារមួយទៅឯកសារមួយទៀតផងដែរ។ ហើយម្យ៉ាងទៀត ក៏យើងត្រូវធ្វើការផ្ទុះបញ្ចាំងពីឯកសារដែលមាននៅក្នុងសំណុំរឿង០០៣, ០០៤ នេះ ទាក់ទងទៅនឹងឯកសារនៃសំណុំរឿង ០០២ ដែលមានស្រាប់នោះផងដែរ។ ហើយកិច្ចការទាំងអស់នេះ គឺត្រូវការពេលវេលាច្រើនដើម្បីធ្វើការត្រួតពិនិត្យ។

[១៤:១៩:២៦]

ចំណុចទី២ មិនត្រូវភ្លេចទេថា ឯកសារទាំងនោះមិនមែនជាឯកសារដែលចាត់ចូលទៅក្នុងសំណុំរឿងដោយស្វ័យប្រវត្តិនោះទេ។ ឯកសារទាំងនោះអាចត្រឹមថាជាឯកសារដែលជូនដំណឹងដោយសហព្រះរាជអាជ្ញាមកចំពោះភាគីយើងតែប៉ុណ្ណោះ។ ឯកសារដែលដាក់ដោយសហព្រះរាជអាជ្ញាទាំងនោះអាចចាត់ទុកជាភស្តុតាងបានកាលបើត្រូវធ្វើតាមកំណត់នៃវិធានផ្ទៃក្នុងដូចមានចែងនៅក្នុងវិធាន ៨៧.៣ និង៨៧.៤។ គឺយើងត្រូវវិភាគឯកសារទាំងអស់នោះ ដើម្បីអាចលើកនូវអញ្ញត្រកម្មពាក់ព័ន្ធនឹងការទទួលឯកសារ។

ទី៣ យើងខ្ញុំមិនប្រាកដថា មានការយល់ឃើញដូចគ្នាឡើយទៅលើអ្វីដែលពាក់ព័ន្ធគ្នាទៅនឹងឯកសារទាំងអស់នោះ ដូចតំណាងសហព្រះរាជអាជ្ញាបានលើកពីម្សិលមិញជាដើម ព្រោះថាយើងមានការយល់ ឬក៏មានយុទ្ធសាស្ត្រខុសៗគ្នាចំពោះរឿងក្តី ចំពោះការការពារកូនក្តីរៀងៗខ្លួនផងដែរ។ ដូច្នេះមិនថាភាពខុសគ្នារវាងក្រុមមេធាវីការពារ និងការយល់ឃើញខុសគ្នារបស់សហព្រះរាជអាជ្ញានោះទេ សូម្បីតែក្នុងក្រុមមេធាវីការពារដូចគ្នា រវាងក្រុមលោក នួន ជា និងក្រុមលោក ខៀវ សំផន ក៏មានចំណុចខ្វែងគ្នា ខុសគ្នា មានការយល់ឃើញខុសគ្នាពីការជាប់ពាក់ព័ន្ធនៃឯកសារទាំងអស់នោះផងដែរ។

ទី៤ យើងត្រូវធ្វើការចាត់ថ្នាក់ឲ្យបានដាច់ពីគ្នានៅក្នុងសំណុំឯកសារដ៏ច្រើនសម្បើមនេះរវាងសេចក្តីថ្លែងការណ៍របស់សាក្សី ដែលលើកឡើងផ្តល់សក្ខីកម្មនៅក្នុងសវនាការនៅក្នុងសំណុំរឿងនេះ។ សាក្សីដែលបានមកផ្តល់សក្ខីកម្មរួចហើយ និងអ្នកដែលត្រូវឡើងមកផ្តល់សក្ខីកម្មនៅពេលខាងមុខទៀតផងដែរ។ គឺយើងត្រូវធ្វើឲ្យបានដាច់ពីសេចក្តីថ្លែងការណ៍ផ្សេងៗទៀត។ សេចក្តីថ្លែងការណ៍របស់សាក្សីដែលឡើងផ្តល់សក្ខីកម្មក្នុងសវនាការត្រូវតែអាចយកមកប្រើប្រាស់ភ្លាមៗបាន។ យើងក៏ត្រូវធ្វើដូចគ្នា

នេះដែរ ចំពោះសម្រង់សេចក្ដីនៃសេចក្ដីថ្លែងការណ៍របស់អ្នកដទៃទៀត ដែលនឹងត្រូវលើកឡើងផ្ដល់សក្ខីកម្មក្នុងពេលសវនាការ។ ប៉ុន្តែ សេចក្ដីថ្លែងការណ៍ដទៃទៀតមិនត្រូវយកមកប្រើប្រាស់ឡើយដរាបណាមិនមានសេចក្ដីសម្រេចលើភាពដែលអាចទទួលយកបាននៃឯកសារទាំងនោះ។

[១៤:២៣:០៧]

ទី៥ យើងខ្ញុំមិនមែនជាភាគីដែលអាចចូលមើលឯកសារ និងធ្វើការស៊ើបអង្កេតនៅក្នុងសំណុំរឿង០០៣ និង ០០៤ឡើយ។ ម្យ៉ាងទៀត យើងមានឧទាហរណ៍ពីភាពមិនត្រឹមត្រូវនៃឯកសារនៅក្នុងកំណត់ហេតុដែលបានលើកឡើងនៅក្នុងសវនាការ ដូចសាក្សី វ៉ាន់ សឿន កន្លងទៅនេះ គឺមានភាពខុសគ្នារវាងការផ្ដល់សក្ខីកម្មដែលមាននៅក្នុងកំណត់ហេតុ និងការមកឆ្លើយបំភ្លឺចំពោះមុខអង្គជំនុំជម្រះ។ យើងត្រូវប្រុងប្រយ័ត្នចំពោះសេចក្ដីថ្លែងការណ៍ទាំងនោះ ពីព្រោះយើងខ្ញុំមិនមានលទ្ធភាពពិនិត្យមើលអ្វីដែលបាននិយាយនៅក្នុងខ្សែអាត់ថតសំឡេង--

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកតំណាងសហព្រះរាជអាជ្ញា សហព្រះរាជអាជ្ញាអន្តរជាតិ!

**លោក នីកូឡាស គូមជែន៖**

ខ្ញុំសូមអភ័យទោសចំពោះមេធាវីការពារក្ដី។ ខ្ញុំមិនចង់រំខានគាត់នោះទេ ប៉ុន្តែខ្ញុំត្រូវតែរំខាន។ ខ្ញុំឮមេធាវីការពារក្ដីនិយាយអំពីឈ្មោះសាក្សីមួយចំនួន ហើយនៅក្នុងនេះគឺថា វាជាការប្រជុំជាសាធារណៈ ដូច្នេះកុំ មេត្តាកុំនិយាយឈ្មោះសាក្សីឱ្យចំៗពេលណាយើងនិយាយអំពីសំណុំរឿង ០៣ និង០៤ នោះ។

**លោក គង់ សំអុន៖**

លោកប្រធាន ខ្ញុំសូមអនុញ្ញាតឆ្លើយតប។ ដោយសារតែសាក្សីនេះបានមកឆ្លើយនៅក្នុងសវនាការនេះរួចហើយ ទើបដូច្នេះបានខ្ញុំ ថាអាចហៅឈ្មោះបានបាទ។

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

វិធានជាទូទៅ សូមមេត្តាកុំនិយាយឈ្មោះសាក្សី ហើយអង្គជំនុំជម្រះ ដឹងនូវអ្វីៗដែលយើងបានធ្វើចំពោះពាក់ -- ឯកសារទាំងអស់នេះ សូមឱ្យផ្ដោតតែការយកចិត្តទុកដាក់តែបញ្ហាពាក់ព័ន្ធ ប្រធានបទដែលពាក់ព័ន្ធតែប៉ុណ្ណោះបានហើយ។

**លោក គង់ សំអុន៖**

បាទ សូមអរគុណ ខ្ញុំសូមបន្ត។ ដូច្នេះ បញ្ហាសេចក្ដីថ្លែងការណ៍របស់សាក្សីទាំងអស់នេះ ដែល

យើងត្រូវយកមកពិនិត្យ អំពីអ្វីដែលជាសក្ខីកម្ម ដែលមានសរសេរនៅក្នុងកំណត់ហេតុ និងផ្ទៀងផ្ទាត់ជាមួយនឹងខ្សែអាត់ថតសំឡេងថា តើវាមានកំហុសក្នុងការធ្វើកំណត់ហេតុ ឬក៏មានចំណុចខ្វះខាត ដែលនាំឲ្យមានការភ័ន្តច្រឡំក្នុងការធ្វើកំណត់ហេតុនោះដែរឬទេ។

ទី៦ យើងខ្ញុំធ្លាប់បានទទួលបទពិសោធន៍រួចហើយពីការទទួលបាននូវឯកសារយ៉ាងច្រើនសម្បើមនៅក្នុងសំណុំរឿង០០២/០១ ដល់ចូលរួមក្នុង -- ដែលបញ្ហានេះ ចូលរួមនៅក្នុងការរំលោភបំពានលើសិទ្ធិទទួលបាននូវការជំនុំជម្រះប្រកបដោយសមធម៌ សម្រាប់លោក ខៀវ សំផន ហើយដែលយើងមិនត្រូវឲ្យជាន់ដាននូវបទពិសោធន៍ចាស់បែបនេះទេ។

[១៤:២៧:១២]

ទី៧ ប្រសិនបើភាគីណាមួយ គិតថាសេចក្តីថ្លែងការណ៍មានអត្ថប្រយោជន៍សម្រាប់ស្វែងរកការពិត ភាគីនោះត្រូវតែស្នើសុំឲ្យសាក្សីឡើងផ្តល់សក្ខីកម្មដោយអនុលោមទៅតាមច្បាប់ដែលត្រូវអនុវត្តធ្វើយ៉ាងណាឲ្យមានការពិភាក្សាដេញដោលនិងការតទល់គ្នានៅក្នុងពេលសវនាការ។ ចំណុចនេះ អាចធ្វើឲ្យយើងយកចិត្តទុកដាក់និងពិនិត្យទៅលើសក្ខីកម្មរបស់សាក្សីដែលក្នុងករណីខ្លះ យើងអាចស្នើសុំអង្គជំនុំជម្រះ ឲ្យកោះហៅសាក្សីមកសាជាថ្មី ក្នុងករណីដែលអង្គជំនុំជម្រះមិនបានផ្តល់ពេលវេលាឲ្យយើងបានគ្រប់គ្រាន់ក្នុងការពិនិត្យទៅលើសក្ខីកម្មទាំងឡាយរបស់សាក្សី ដែលបានដាក់ដោយសហព្រះរាជអាជ្ញានេះ។ ទោះយ៉ាងណាក្តី ក្នុងពេលឥឡូវនេះ យើងខ្ញុំសូមពេលវេលាឲ្យបានគ្រប់គ្រាន់ ដើម្បីពិនិត្យមើលឯកសារ ដែលបានជូនដំណឹងដល់សហព្រះរាជអាជ្ញាក្នុងសំណុំរឿង ០០៣ និង០០៤នេះ។ យើងខ្ញុំមិនអាចបន្តទៅមុខដោយមិនបានពិនិត្យទៅលើឯកសារទាំងអស់នោះឲ្យបានគ្រប់ជ្រុងជ្រោយនោះទេ។

នេះគឺជាយោបល់របស់យើងដែលមានសម្រាប់ពេលឥឡូវនេះ។ បាទសូមអរគុណលោកប្រធាន។

**ប្រធានអង្គប្រជុំ៖**

បាទសូមអញ្ជើញលោកស្រីចៅក្រម ក្លូឌា ហ្វេនស៍!

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

ខ្ញុំៗលើកឡើងបញ្ហាជាក់លាក់មួយចំនួន។ ខ្ញុំយល់ថា យើងមិនអាចឆ្លើយបញ្ហានេះឥឡូវនេះបានទេ ប៉ុន្តែសួរសំណួរនៅពេលដែលភាគីដទៃទៀតធ្វើការផ្តល់ជាមតិយោបល់នោះ។ ជាពិសេសនៅក្នុងពេលនេះតែម្តង ថាតើការ -- តើក្រុមមេធាវីការពារក្តីត្រូវការពេលវេលាប៉ុន្មានទៀត ដើម្បីរៀបចំការការពារក្តីនេះ?

[១៤:៣០:០០]

**លោក នីកូឡាស គូមជែន៖**

ខ្ញុំច្រឡំថាឲ្យមេធាវីការពារក្ដីឆ្លើយតប សូមអធ្យាស្រ័យ។

លោកប្រធាន លោក លោកស្រីចៅក្រមដំបូងសូមឲ្យខ្ញុំលើកឡើងថា សហព្រះរាជអាជ្ញាទទួលស្គាល់ថានេះគឺជាបញ្ហាមួយដែលលំបាក ដែលយើងមានការបង្ហាញឯកសារបន្តជាហូរហែនៅក្នុងពេលធ្វើការជំនុំជម្រះ។ វាជាការដាក់បន្ទុកទៅលើភាគីទាំងអស់ គឺទៅលើភាគីការពារក្ដី ទៅលើការយកចិត្តទុកដាក់របស់អង្គជំនុំជម្រះ យើងធ្វើការយ៉ាងយកទុកចិត្តដាក់អស់រយៈពេលជាច្រើនខែ ព្យាយាមដើម្បីស្នើសុំឲ្យមានការបង្ហាញនូវឯកសារទាំងអស់នេះ នៅក្នុងមធ្យោបាយមួយឲ្យបានឆាប់រហ័ស។ ការណ៍ដែលនិយាយបែបដូច្នេះ ហើយនេះក៏ជាចម្លើយពាក់ព័ន្ធទៅនឹងការជំទាស់តវ៉ារបស់មេធាវីការពារក្ដីដោយសារថាសំណើរបស់គាត់គឺមានច្របាច់ចូលគ្នានូវបញ្ហានៅចំពោះមុខតុលាការកំពូល បញ្ហាបណ្ដឹងសាទុក្ខ បញ្ហានៅចំពោះមុខសហចៅក្រមស៊ើបអង្កេត បញ្ហានៃការដាក់បង្ហាញឯកសារ និងការតវ៉ានៅទីនេះដែលថាសហព្រះរាជអាជ្ញាបង្ហូរឯកសារយ៉ាងច្រើន គេនិយាយអំពីចំនួនទំព័រដ៏ច្រើន។ ហើយក៏ស្នើសុំឲ្យអង្គជំនុំជម្រះប្រាប់ឲ្យយើងបង្ហាញនូវឯកសារច្រើនទៅទៀតទៅក្នុងសំណុំរឿងនេះ។

[១៤:៣១:៣៤]

ហើយមេធាវីការពារក្ដីក៏បានតវ៉ា ថាគេបានទទួលឯកសារនេះវាយឺតពេលទៅហើយ។ យើងបាននិយាយអំពីបញ្ហាបង្ហាញឯកសារនៅក្នុងសំណុំរឿង០៣, ០៤។ ចាប់ -- ប្រហែលជាចាប់តាំងពីមុនចាប់ផ្ដើមជំនុំជម្រះសំណុំរឿងនេះទៅទៀត កាលពីឆ្នាំម្ល៉េះ។ ការស៊ើបអង្កេតសំណុំរឿង០៣, ០៤ នៅតែបន្តធ្វើតទៅទៀត ហើយសហចៅក្រមស៊ើបអង្កេតបានបង្ហាញអំពីទីតាំងឧក្រិដ្ឋកម្មនៅក្នុងសំណុំរឿង ០៣, ០៤ មេធាវីការពារគាត់ដឹងបញ្ហានេះតាំងពីយូរយារណាស់មកហើយ មុននឹងយើងចាប់ផ្ដើមជំនុំជម្រះសំណុំរឿង០២/០២ទៅទៀត។

ដូច្នេះមេធាវីការពារក្ដីក៏បានអ្វីដែលគេនិយាយ គឺឯកសារមានការពាក់ព័ន្ធខ្លាំងណាស់ទៅដល់ក្រុមរបស់គាត់។ ដូច្នេះគេតវ៉ាពីចំនួនឯកសារហ្នឹងថាច្រើន ហើយគេចង់បានឯកសារណាពាក់ព័ន្ធឲ្យបានច្រើនថែមមកទៀត។ យើងចង់ធ្វើការជាមួយនឹងអង្គជំនុំជម្រះ ជាមួយមេធាវីការពារក្ដីដើម្បីស្វែងរកមធ្យោបាយ ដើម្បីឲ្យនីតិវិធីជឿនលឿនទៅមុខ កុំឲ្យមានការបន្ទច់បង្អាក់ដល់កិច្ចដំណើរការនីតិវិធី។ ហើយមេធាវីការពារក្ដីថាចង់បន្តការជំនុំជម្រះឲ្យបានជាលឿនទៅមុខដែរ។

ដូច្នេះយើងត្រូវតែដោះស្រាយបញ្ហានៃសំណើរបស់មេធាវីការពារក្ដីម្ដងមួយៗ។ ទី១ ទាក់ទងទៅនឹងការសុំផ្អាកសវនាការ។ យើងខ្ញុំមិនជឿថាវាមានការចាំបាច់ ចំនួនឯកសារដែលមានមេធាវីការពារក្ដីលើកយមកនិយាយនេះប្រហែលជាតិចជាង៣០០០ទំព័រ ទាក់ទងទៅនឹងច្បាប់ -- ករណីនៅចំពោះមុខតុលាការព្រហ្មទណ្ឌអន្តរជាតិ វាចំនួនឯកសារនេះតិចណាស់ បើប្រៀបធៀបទៅ។ បើយើងមើលសំណុំរឿង មីឡូសីវិច យើងឃើញថា សហព្រះរាជអាជ្ញាបន្តសុំបង្ហាញឯកសារដល់ប្រហែល ១៥.០០០ទំព័រឯណោះ ឬក៏ច្រើនជាងនេះទៅទៀតនៅពេលនោះ បង្ហាញទៅឲ្យមេធាវីការពារក្ដីពិនិត្យមើល។ ដូច្នេះមិនមែនតែរឿងបញ្ហាចំនួនឯកសារទេ តែករណីនេះវាមានភាពស្មុគស្មាញទៀតផង។

[១៤:៣៣:៤៨]

យើងក៏បានឃើញមេធាវីការពារក្ដីព្យាយាមដោះសាថា វាមិនចាំបាច់សួរតទល់ជាមួយនឹងសាក្សីដែលត្រូវចូលខ្លួននោះទេ។ គេនិយាយនេះជាទូទៅនេះទេ ដោយសារថាសាក្សីនេះ គឺជាថ្នាក់ដឹកនាំកម្មាភិបាល ហើយគេគ្មានពេលវេលាដើម្បីពិនិត្យមើលឯកសាររបស់សាក្សីនេះទេ។ ប៉ុន្តែនៅពេលឯកសារដែលត្រូវបានបង្ហាញ ឬក៏នឹងត្រូវបង្ហាញ គឺត្រូវតែយកមកសួរតទល់ជាមួយសាក្សីរូបនេះ។ យើងឮមេធាវីការពារក្ដី នួន ជា អះអាងថា ឯកសារដែលគេបានទទួលថ្មីៗនេះ អាចនឹងធ្វើឲ្យគេកែប្រែនូវសំណួរដែលគេរៀបចំសួរទៅលើសាក្សី។ គេបាន -- គេមិនបានពន្យល់ថាអ្វីខ្លះនោះទេ។ តើសំណួរអ្វីខ្លះដែលគួរតែសួរ សំណួរអ្វីដែលគេមិនសួរនោះទេ។ ក៏ប៉ុន្តែតេស្តហ្នឹងគឺថាតើៗវាមានផលប៉ះពាល់ប៉ុនណាទាក់ទងទៅនឹងសាក្សីរូបនេះ។ ជាពិសេសមេធាវីការពារក្ដីមិនបានព្យាយាមពន្យល់បញ្ហានេះទេ ប៉ុន្តែយើងទទួលស្គាល់ថា វាអាចមានស្ថានភាពបែបនេះកើតឡើងនៅពេលដែលបង្ហាញឯកសារ វាមិនមានប៉ះពាល់យ៉ាងខ្លាំងទៅដល់សក្ខីកម្មរបស់សាក្សី ដែលបានឆ្លើយរួចហើយ។ ក្នុងករណីបែបនេះ នីតិវិធីគឺថាភាគីត្រូវស្នើសុំទៅអង្គជំនុំជម្រះ ដែលថាឯកសារណាមួយវាចាំបាច់ត្រូវតែពិនិត្យឡើងវិញ ត្រូវតែពិនិត្យនោះ។ ដូច្នេះតុលាការនឹងថ្លឹងថ្លែងថា តើវាមានភាពពាក់ព័ន្ធយ៉ាងម៉េចរវាងឯកសារ ហើយនិងសក្ខីកម្មរបស់សាក្សីរូបនេះ ដើម្បីរកមធ្យោបាយណាដែលមានលក្ខណៈសមស្រប កុំឲ្យមានការពន្យារសវនាការដោយមិនមានមូលហេតុ។ ដូច្នេះ យើងខ្ញុំយល់ឃើញថា វាអាចធ្វើទៅបាន ហើយការជំនុំជម្រះត្រូវតែបន្តធ្វើទៅមុខទៀត ដោយបន្តឯកសារបែបនេះជាហូរហែរតទៅទៀត។ ដោយសារតែការស៊ើបអង្កេតក៏កំពុងតែបន្តទៅដែរ ដូច្នេះ ការសុំបង្ហាញឯកសារក៏នឹងបន្តបង្ហាញតទៅមុខទៀតដែរ។ ហើយយើងបានស្នើសុំឲ្យសហចៅក្រមស៊ើបអង្កេតធ្វើការសម្រេចសេចក្ដី ពាក់ព័ន្ធទៅនឹងការបង្ហាញ

ឯកសារដែលៗទាមទារឲ្យមានការពិនិត្យឡើងវិញនូវចម្លើយរបស់សាក្សី តើឯកសារណាវាជាឯកសារមួយវាមានការប៉ះពាល់ខ្លាំងទៅដល់សាក្សី។ ហើយនិយាយដោយស្មោះទៅ ខ្ញុំមានការសង្ស័យដែរថាប្រហែលជាវាត្រូវការពេលវេលាណាស់ មុននឹងពេលប្រកាសគ្រប់បុគ្គលទាំងអស់ដែលត្រូវចោទប្រកាន់ដោយកំបាំងមុខនេះ ទៅលើករណីទាំងអស់នៅចំពោះមុខសហចៅក្រមស៊ើបអង្កេត។ យើងក៏ត្រូវចូលរួមពាក់ព័ន្ធ និងឆ្លើយតបទៅនឹងបញ្ហាទាំងអស់នេះដែរ។ ដូច្នេះ បន្ទុកនៃការងាររបស់យើង ក៏ធ្ងន់ធ្ងរនោះដែរ។

[១៤:៣៦:៤២]

សំណើទី២ គឺការកំណត់កិច្ចប្រជុំសវនាការ គឺយើងកំពុងតែធ្វើហើយ។ សំណើទី៣ ទាក់ទងទៅនឹងកថាខណ្ឌ(គ) ដែលត្រូវពិគ្រោះយោបល់ជាមួយនឹងមេធាវីការពារក្តី។ ជំហររបស់យើងគឺថា យើងត្រូវតែធ្វើទៅតាមនីតិវិធីដែលបានកំណត់មកដល់ពេលនេះហើយ។ ហើយសំណើសុំ ឌី មេធាវីការពារក្តីសវនាការវគ្គបន្ទាប់ គឺនៅ -- យើងមកនិយាយអំពីទំនប់១មករា យើងមិនជំទាស់ទេ។ ហើយសូមឲ្យមានការកែប្រែនូវកំណត់ការបរិច្ឆេទសវនាការដោយត្រឡប់ទៅនិយាយ -- ដោយសារទីតាំងនេះគឺថា វាមានពាក់ព័ន្ធទៅនឹងចម្លើយសាក្សីច្រើន។

នៅក្នុងកថាខណ្ឌ (ង) មេធាវីការពារក្តីស្នើសុំឲ្យអង្គជំនុំជម្រះនៅពាក់កណ្តាលទីបែបនេះ ដែលថាខ្មែរក្រោមមិនបានដាក់បញ្ចូលទៅក្នុង -- សូមដកស្រង់៖ “ក្រុមគោលដៅនៅក្នុងសំណុំរឿង០០២/០២នេះទេ”។ បទចោទនៅក្នុងករណីនេះ គឺៗបទចោទគឺជាបទចោទ មិនមែនជាដីកាដំណោះស្រាយនោះទេ។ មេធាវីការពារក្តីស្នើសុំឲ្យអង្គជំនុំជម្រះធ្វើបែបនេះ ដោយគេជំទាស់ទៅលើបញ្ហានេះ គឺថា ដើម្បីការពារកុំឲ្យមានភស្តុតាងណាដែលគេត្រូវបានប្រព្រឹត្ត -- បង្ហាញថាបានប្រព្រឹត្តឡើងប្រឆាំងទៅនឹងខ្មែរក្រោម។ ហើយយើងជំទាស់ទៅនឹងបញ្ហានេះ ខ្មែរក្រោមទទួលការរងទុក្ខ ពួកគេជាជនរងគ្រោះដោយមូលហេតុផ្សេងៗ ដូចជាគ្រាន់តែ លួចដួង លួចអីយ៉ាងដូច្នេះ។ ហើយៗក៏គេចាត់ទុកអ្នកទាំងអស់នោះថាខ្មែរ ដោយសារគ្រាន់តែលួចដូងយ៉ាងដូច្នេះដែរ ដោយសារថាពួកគេមានប្រភពដើមចេញមកពីទឹកវៀត-ណាម គេចាត់ទុកអ្នកទាំងនោះថាជាខ្មាំង។ ហើយគេកំណត់គោលដៅមកលើក្រុមទាំងនេះ ដែលខ្មែរក្រហមកំណត់ជាក្រុមគោលដៅថាជាខ្មាំង។ ក្នុងករណីនេះ ភស្តុតាងមិនគួរណាត្រូវដកចេញនោះទេ។

[១៤:៣៩:០៨]

កថាខណ្ឌ(ច) មេធាវីការពារក្តីស្នើសុំឲ្យអង្គជំនុំជម្រះឲ្យសហព្រះរាជអាជ្ញាអន្តរជាតិបង្ហាញទៅ

ភាគីទាំងអស់អំពីភស្តុតាងនៅក្នុងសំណុំរឿង០៣និង០៤ និងស្នើសុំឱ្យសហចៅក្រមស៊ើបអង្កេតអន្តរជាតិបង្ហាញឯកសារទាំងអស់នេះឱ្យបានឆាប់រហ័សតាមដែលអាចធ្វើទៅបាន។ ខ្ញុំយល់ស្របទាំងស្រុងជាមួយនឹងសំណើសុំនេះ។ ហើយចុងក្រោយ មេធាវីការពារក្ដីស្នើសុំឱ្យអង្គជំនុំជម្រះបង្ហាញពីស្ថានភាពដែលៗរឹតត្បិតមិនរឹតបន្តឹងទៅលើមេធាវីការពារក្ដី ពាក់ព័ន្ធទៅនឹងឯកសារដែលបាន -- ដែលយកចេញមកពីសំណុំរឿង០៣និង០៤។ តាមច្បាប់ គឺថា ខ្ញុំមិនបាច់ជម្រាបជូនអង្គជំនុំជម្រះ គឺថា ច្បាប់ អ.វ.ត.ក ការស៊ើបអង្កេតគឺជាការសម្ងាត់។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិប្រហែលជាមានករណីលើកលែងពាក់ព័ន្ធទៅនឹងភាពសម្ងាត់ ដើម្បីធានាថាអង្គជំនុំជម្រះសាលាដំបូង មេធាវីការពារក្ដី ភាគីទាំងអស់មានព័ត៌មានពាក់ព័ន្ធទៅនឹងសំណុំរឿង០២ ដែលយកឯកសារចេញពី ០៣ និង ០៤។ បើតាមខ្ញុំយល់នោះ គឺខ្ញុំគឺថាបើសិនមានការដាក់បន្ទុកបែបនេះមែន គាបសង្កត់បែបនេះ ខ្ញុំមានការអាណិតអាសូរទៅដល់ពួកគេណាស់ តែយើងត្រូវស្នើសុំទៅសហចៅក្រមស៊ើបអង្កេតអន្តរជាតិ។ ខ្ញុំគាំទ្រថាឱ្យមានការសម្រួលឥរិយាបទសម្រាកខ្លះទៅ កុំតឹងតែងពេក។ ខ្ញុំយល់ឃើញថាមេធាវីការពារក្ដីធ្វើបែបនេះ ស្មានថាគេនឹងគោរពទៅដល់ភាពសម្ងាត់នៃកិច្ចស៊ើបសួរ។ ដូច្នេះស្នើសុំទៅសហចៅក្រមស៊ើបអង្កេតទៅ តាមមធ្យោបាយមួយដែលសមស្រប ដែលចៅក្រមស៊ើបអង្កេតគាត់យល់ឃើញថានឹងអនុញ្ញាតទៅបាន។

បើសិនណាជាស្ថានភាពនេះអាចត្រូវបានសម្របសម្រួល ខ្ញុំគាំទ្រទៅដល់មេធាវីការពារក្ដី។ ខ្ញុំសូមនិយាយជាសាធារណៈតែម្ដងថា ខ្ញុំ បើខ្ញុំគាំចំពោះការបន្ធូបន្ថយទៅដល់លក្ខខណ្ឌទាំងអស់នេះ។ ខ្ញុំសូមអនុញ្ញាតឱ្យលោក លីសាក់ លើកបង្ហាញជូនអង្គជំនុំជម្រះចំពោះបញ្ហាពាក់ព័ន្ធបំផុត។

**ប្រធានអង្គជំនុំ៖**

សហព្រះរាជអាជ្ញារងដល់ពេលសម្រាកហើយ។ អង្គជំនុំជម្រះប្រកាសសម្រាកសិនចាប់ពីពេលនេះទៅរហូតដល់ម៉ោងបី សូមអញ្ជើញចូលវិញ។

សម្រាកសិនចុះ!

*(សវនាការសម្រាកពីម៉ោង ១៤:៤២ នាទី ដល់ម៉ោង ១៥:០៨ នាទី)*

[១៥:០៩:០២]

**ប្រធានអង្គជំនុំ៖**

បាទ អង្គុយចុះ!

បាទ បន្តកិច្ចប្រជុំពិភាក្សារបស់យើងបន្តទៅទៀត។ ហើយតទៅនេះ ផ្ដល់វេទិកាជូនទៅសហ

ព្រះរាជអាជ្ញារងអន្តរជាតិ ដើម្បីមាន ឡើងមតិយោបល់ដែលមានបំណងចង់និយាយ។ សូមអញ្ជើញលោក!

**លោក ខេល លីសាក់៖**

សូមអរគុណលោកប្រធាន លោក លោកស្រីចៅក្រម មេធាវីការពារក្តីលើកបញ្ហាមួយចំនួនថា យើងនឹងមិនដាក់សំណើសុំជាលាក់លក្ខណ៍អក្សរទេ គឺយើងប្រើប្រាស់ឱកាសនេះ គឺថាជាការឆ្លើយតបទៅនឹងបញ្ហាដ៏ច្រើនដែលមេធាវីការពារក្តីលើកឡើង។ បញ្ហាមួយដែលខ្ញុំចង់ផ្តើមយកមកនិយាយ គឺសហព្រះរាជអាជ្ញាអន្តរជាតិ បញ្ជាក់ថាយើងបើកឱ្យមានការចំហសម្រាប់ពិភាក្សា ថាតើលំដាប់លំដោយបែបម៉េចសម្រាប់សវនាការនៅថ្ងៃខាងមុខនោះ។ អ្វីដែលយើងមិនយល់ស្របនោះ គឺសំណើសុំដោយមេធាវីការពារក្តី ថាយើងត្រូវផ្អាកសវនាការសព្វថ្ងៃនេះ បច្ចុប្បន្ននេះ ពាក់ព័ន្ធទៅនឹងស្រុកត្រាំកក់សិន ហើយយើងលើកសវនាការនិយាយអំពីភូមិភាគផ្សេងទៅវិញ ដូចជាទំនប់១មករា ជាដើមនោះ។

ខ្ញុំជម្រាបជូនអង្គជំនុំជម្រះថា ហេតុម៉េចបានយើងមិនយល់ស្រប។ ទី១ មេធាវីការពារក្តីមើលរំលងទៅលើភូមិភាគកណ្តាល ជាភូមិភាគមួយដ៏ធំនៃការស៊ើបអង្កេតនៅក្នុងសំណុំរឿង០៤។ រួមទាំងមន្ទីរសន្តិសុខដែលពាក់ព័ន្ធទៅនឹងទំនប់១មករា គឺជាការចោទប្រកាន់ពាក់ព័ន្ធទៅនឹងផ្នែកមួយនៃទំនប់១មករា ដែលវាជាផ្នែកមួយនៃសំណុំរឿង០៤។ ជាមួយនេះដែរ គឺថាវាពាក់ព័ន្ធទៅនឹងទីតាំងឧក្រិដ្ឋកម្មនៅក្នុងភូមិភាគកណ្តាល។ ក.ស.ច.ស មិនទាន់បានធ្វើកិច្ចសម្ភាសន៍ទាក់ទងទៅនឹងមន្ទីរសន្តិសុខពីរ ឬក៏មិនទាន់បានធ្វើការស៊ើបអង្កេតពាក់ព័ន្ធទៅនឹងទំនប់១មករានៅឡើយទេ។ ប៉ុន្តែមានឯកសារមួយចំនួនតូចទេ ក៏ប៉ុន្តែយើងក៏អត់ដែរ យើងខ្ញុំអត់ដឹងថាតើសហចៅក្រមស៊ើបអង្កេតនឹងត្រូវស៊ើបសួរយ៉ាងដូចម្តេចពាក់ព័ន្ធទៅនឹងទីតាំងទាំងអស់នោះ។ យើងមានជនសង្ស័យដែលធ្វើ -- ស្នើសុំចូលរួមនៅក្នុងការស៊ើបអង្កេត។ នេះគឺជាបញ្ហាមួយដែលភាគីទាំងអស់ត្រូវជ្រាប។ សំខាន់ជាងនេះទៅទៀត យោងទៅលើគម្រោងផែនការលំដាប់លំដោយនៃការជំនុំជម្រះ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានផ្តល់អាទិភាពទៅឱ្យបង្ហាញឯកសារមួយចំនួន ហើយគាត់បានមផ្តល់អាទិភាពដើម្បីធានាថាការបង្ហាញឯកសារទាំងអស់នោះ ទាក់ទងទៅនឹងស្រុកត្រាំកក់ ក្រាំងតាចាន់ជាដើម។ល។

[១៥:១២:០២]

ប៉ុន្តែចៅក្រមស៊ើបអង្កេតមិនអនុញ្ញាតឱ្យបង្ហាញនូវកិច្ចសម្ភាស ដែលកំពុងតែធ្វើឡើងពាក់ព័ន្ធទៅនឹងភូមិភាគកណ្តាលនៅឡើយទេ។ មិនទាន់មាននៅឡើយទេ។ ដូច្នេះ អ្វីដែលមេធាវីការពារក្តីស្នើសុំ

នោះ តើយើងត្រូវបញ្ឈប់វគ្គជំនុំជម្រះ ហើយរង់ចាំការទទួលឯកសារៗពាក់ព័ន្ធទៅនឹងភូមិភាគនិរតីនោះ គឺឯកសារសន្តិសុខត្រាំកក់ គឺបានបង្ហាញហើយ។ ប៉ុន្តែបើយើងចង់ជំនុំជម្រះទៅលើភូមិភាគផ្សេង គឺឯកសារមិនទាន់មាននៅឡើយ គ្មានន័យអីនោះទេសំណើបែបនេះ។ ហើយវានឹងពាក់ព័ន្ធទៅនឹងចំណុចបន្ទាប់។ ការជំទាស់ការតវ៉ាមួយទៀត ការបង្ហាញឯកសារនេះ ជាការរំលោភទៅដល់សិទ្ធិជំនុំជម្រះប្រកបដោយយុត្តិធម៌របស់កូនក្តីខ្លួន។ វាជាការផ្ទុយទៅវិញទេ។

គោលបំណងនៃការបង្ហាញឯកសារទាំងអស់នេះ ដើម្បីធានាថា មេធាវីការពារក្តីទទួលបានសិទ្ធិជំនុំជម្រះប្រកបដោយយុត្តិធម៌។ ធានាថាពួកគេទទួលបាននូវចម្លើយ និងព័ត៌មានពាក់ព័ន្ធទាំងអស់ និងភស្តុតាងពាក់ព័ន្ធចេញពីសំណុំរឿង០៣ និង០៤។

ការបន្តទៅធ្វើទៅលើទីតាំងឧក្រិដ្ឋកម្មភូមិភាគផ្សេង ដោយសារតែចម្លើយនោះ មិនទាន់បានដាក់បង្ហាញនៅឡើយ វាកាន់តែបង្កបញ្ហាទៅទៀតហើយ។ វាកាន់តែបង្កបញ្ហា ជាជាងការបន្តជំនុំជម្រះទៅលើផ្នែកដែលកំពុងតែជំនុំជម្រះ។ ខ្ញុំយល់ឃើញថា នេះគឺជាការបង្ហាញភស្តុតាងមួយ ជូនអង្គជំនុំជម្រះពិចារណា។

[១៥:១៣:៣៦]

ខ្ញុំសូមឆ្លើយតបទៅនឹងបញ្ហាមួយចំនួនទៀត គឺបញ្ហាថាតើមានឯកសារដទៃទៀត បន្ថែមទៅលើចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី ឬក៏សាក្សីនោះទេ។ ខ្ញុំមិនអាចជម្រាបបានទេ ឯកសារនៅក្នុងពេលហ្នឹង ថាតើវាមានទំហំដូច វាមានទំហំច្រើនដូចនៅក្នុងសំណុំរឿង០២/០២ ឬក៏អត់។

សហចៅក្រមស៊ើបអង្កេត គឺបានទៅមើលនៅឯមជ្ឈមណ្ឌលឯកសារកម្ពុជា ដើម្បីរកឯកសារណាដែលពាក់ព័ន្ធ។ ដូច្នេះ ក.ស.ច.ស កំពុងតែពិនិត្យមើលឯកសារទាំងអស់នេះ។ បើសិនណាជាមានលក្ខណៈសមស្រប យើងនឹង -- ប៉ុន្តែ ក.ស.ច.ស មកដល់ហ្នឹង គឺតាមដែលយើងដឹង មិនទាន់បានបង្ហាញ -- ទទួលបាននូវឯកសារពីនោះនៅឡើយទេ។

បញ្ហាបង្ហាញឯកសារទាំងអស់នេះជាផ្នែកៗ។ ខ្ញុំសូមបញ្ជាក់ សំណើសុំដំបូងរបស់យើងទៅ ក.ស.ច.ស ប្រហែលជា១ឆ្នាំកន្លងទៅហើយ គឺស្នើសុំឲ្យបង្ហាញឯកសារពាក់ព័ន្ធទាំងអស់ -- ចម្លើយពាក់ព័ន្ធទាំងអស់។ ក.ស.ច.ស មិនមានចេតនាបង្ហាញទេ ដោយសារមានបញ្ហាថាការស៊ើបអង្កេតកំពុងតែបន្តធ្វើនៅឡើយ។ ហើយដូច្នេះ នៅពេលដែលយើងដាក់សំណើសុំថ្មីទៀត នៅពេលយើងកំណត់កាលបរិច្ឆេទសវនាការនេះទៅ យើងក៏បានស្នើសុំម្តងទៀតឲ្យបង្ហាញនូវឯកសារពាក់ព័ន្ធពាក់ទាំងអស់។ ហើយ

ជាជម្រើសទៅវិញនោះ តាមការសម្តែងនូវការព្រួយបារម្ភ យើងក៏បានឲ្យបញ្ជីនៃឯកសារហ្នឹង ដើម្បីបង្ហាញទៅសហចៅក្រមស៊ើបអង្កេតថា សវនាការនឹងជំនុំជម្រះទៅតាមលំដាប់លំដោយ ដូចជាកម្មវត្ថុដែលក្រុមមេធាវីការពារក្តី នួន ជា បានលើកឡើង នៅក្នុងបណ្តឹងសាទុក្ខប្រឆាំង -- សាលក្រមសំណុំរឿង០០២/០១។ យើងមានបញ្ជីឯកសារជាអត្ថិភាព ប៉ុន្តែសហចៅក្រមស៊ើបអង្កេតមិនមានចេតនាបង្ហាញឯកសារនេះនៅក្នុងពេលនោះទេ។ អ្វីដែលយើងអាចធ្វើទៅបានគឺយើងត្រូវធ្វើសំណើសុំទៅសហចៅក្រមស៊ើបអង្កេត អ្វីដែលបានបង្ហាញ អ្វីដែលបានស្នើសុំ ហើយមិនទាន់បង្ហាញ។

[១៥:១៦:២១]

នៅពេលសំណើសុំបែបហ្នឹង ដែលស្នើសុំថា -- ដែលលើកឡើងថា នេះគឺជាផែនការរបស់យើងដែលយើងថាយើង គឺថាវាទៅជាឃុបឃិតជាមួយនឹងសហចៅក្រមស៊ើបអង្កេត ទម្លាក់ឯកសារទាំងដុំៗមកយ៉ាងដូច្នេះ។ យើងមិនជំទាស់ពាក់ព័ន្ធទៅនឹងចម្លើយសាក្សីដែលត្រូវបង្ហាញនៅពេលក្រោយ ប្រសិនណាជាគេលើកឡើងទៅតាមផ្លូវច្បាប់នូវបញ្ហាសំខាន់ៗដែលមិនទាន់បានលាតត្រដាងនៅឡើយ បង្ហាញនៅឡើយ សូមដាក់សំណើនោះទៅ សុំដាក់បង្ហាញឯក -- សំណើសុំដោយបង្ហាញនូវមូលហេតុជាក់លាក់ ហើយមេធាវីការពារក្តីក៏មានឱកាសដូចយើងដែរ ធ្វើដូចយើងទៅ យើងបានធ្វើសំណើសុំយ៉ាងច្រើន។ ដូច្នេះសេចក្តីរំពឹងរបស់ខ្ញុំថា កាលណាយើងធ្វើសំណើបែបហ្នឹង យើងអាចនឹង -- វាមានដំណោះស្រាយទេតើនៅតុលាការនេះ ការសុំពន្យារសវនាការបែបនេះមិនអាចជៀសវាងនូវការលំបាកបែបនេះបានទេ។

ការជំទាស់តវ៉ាដែលលើកឡើងនៅទីនេះ គឺថាសុំឲ្យផ្តល់ពេលវេលាយើងនោះ គឺថាយើងមិនមានស្អីដែលត្រូវធ្វើឡើងដោយតក់ក្រហល់នោះទេ។ ការស៊ើបអង្កេតកំពុងតែធ្វើបន្តទៅទៀត យើងមិនដឹងថាតើគេត្រូវសម្ភាសសាក្សីណាខ្លះ។ ក.ស.ច.ស បានសម្ភាសអ្នកណាហើយខ្លះហើយទេមកដល់ថ្ងៃនេះ។ គេអាចសម្ភាសសាក្សីដែលអង្គជំនុំជម្រះកោះមកឲ្យបំភ្លឺនៅទីនេះក៏ថាបាន។ អ៊ីចឹងយើងត្រូវស្នើសុំទៅតាមលំដាប់លំដោយ ទៅតាមករណីជាក់ស្តែងតែម្តង។ ខ្ញុំជឿជាក់ថា គេមិនទាន់បានបង្ហាញមធ្យោបាយបែបនេះនៅឡើយទេ។ ក្នុងចំណោមកិច្ចសម្ភាសន៍ដែលត្រូវសម្ភាស១០០ គឺថាទើបតែសម្ភាសបានប្រហែលជា១០តែប៉ុណ្ណោះ នៅឯក្រាំងតាចាន់ហ្នឹង។

មេធាវីការពារក្តីក៏ត្រូវពិនិត្យមើលនូវចម្លើយដទៃទៀត ហើយនិងបញ្ជាក់ឲ្យបានច្បាស់លាស់។ ចម្លើយទាំងអស់វាៗមិនពាក់ព័ន្ធគ្នាទេ ប៉ុន្តែភាគខ្លះវាពាក់ព័ន្ធ។ ហើយសវនាការជំនុំជម្រះគឺថាវាស៊ីពេលវេលាយូរណាស់ ដូច្នេះសំណើសុំជារួមរបស់ខ្ញុំ គិតថាយើងជិតដល់ពេលបញ្ចប់នៃវគ្គទី១ នៃសវនាការ

នេះហើយ។ ឥឡូវនេះទៅជាដល់ពេលស្នើសុំឲ្យពន្យារទៅវិញ យើងគួរតែបន្តទៅមុខទៀត។ នៅពេលយើងបញ្ចប់ផ្នែកនៅក្នុងរយៈពេលប៉ុន្មានសប្តាហ៍ខាងមុខទៀតនេះ ប្រហែលជាពេលនោះជាពេលវេលាដែលត្រូវស្នើសុំឲ្យមានការឈប់សម្រាក ដែលយើងត្រូវចូលជំនុំជម្រះមុននឹងចូលជំនុំជម្រះពាក់ព័ន្ធទៅនឹងផ្នែកផ្សេង។

[១៥:១៩:១២]

ចុងក្រោយ ខ្ញុំនិយាយលើកឡើងអំពីការបង្ហាញនូវឯកសារដែលគេហាមឃាត់ យើងក៏គេដាក់បន្ទុកធ្ងន់ធ្ងរណាស់ គឺថាវា -- ការដាក់បង្ហាញទៅតាមប្រព័ន្ធអេឡិចត្រូនិកនោះគឺយ៉ាងងាយស្រួលជាការសុំឲ្យឯកសាររឹងជាក្រូណូ ផ្តល់ជាក្រូណូមកឲ្យយើង។ ទោះបីជាពួកគេមិនមែនជាភាគី ប៉ុន្តែពួកគេមានអ្នកដែលមិនមែនជាភាគីនៃរឿងក្តីក៏អាចដាក់សំណើសុំ ហើយគេក៏ត្រូវតែបង្ហាញ ដូចជាចៅក្រម ហាម៉ុនថា "ត្រូវតែគោរពទៅដល់កិច្ចសម្ងាត់នៃកិច្ចស៊ើបសួរ"។ ដូច្នេះត្រូវតែបញ្ជាក់ចំណុចនេះ គឺមិនជាយូរប៉ុន្មានទេកាលពីពេលកន្លងទៅ គេលើកក្រោកឈរឡើងថា ហេតុម៉េចបានជាគេមិនទុកចិត្តយើងអំពីភាពសម្ងាត់។ ប៉ុន្តែមួយសប្តាហ៍មុននេះគេប្រកាសនៅក្នុងសវនាការនេះ ហើយនិងប្រាប់ទៅដល់សារព័ត៌មានថា គេមិនមែនជាមន្ត្រីតុលាការ គេមិនមែនជានេះទេ ហើយពួកគេមិនគោរពទៅតាមបញ្ជារបស់តុលាការនោះទេ។ មិនមានការដាក់ទណ្ឌកម្មចំពោះការបង្ហើបបែកការណ៍នូវភាពសម្ងាត់។ នៅពេលណាដែលយើងធ្វើការដូច្នេះ ចៅក្រម ហាម៉ុន គាត់មានហេតុផលដែលគាត់ព្រួយបារម្ភហើយ បានគាត់មិនឲ្យបង្ហាញឯកសារ។ ការដែល -- ការបើសិនណាជាយើងចង់បំពេញបំណងរបស់សហចៅក្រម អ៊ីចឹងត្រូវគោរពគោលការណ៍នៃកិច្ចសម្ងាត់ហ្នឹងទៅ។ ក៏ប៉ុន្តែវាមានមូលហេតុដែលធ្វើឲ្យសហចៅក្រមស៊ើប

អង្កេតមានការព្រួយបារម្ភ។ នេះគឺជាបញ្ហាមួយដែលត្រូវតែដោះស្រាយជាមួយនិងសហចៅក្រមស៊ើបអង្កេត។ ខ្ញុំយល់ឃើញថា ខ្ញុំបានលើកនូវចំណុចទាំងនេះបានចប់សព្វគ្រប់ហើយ។ ដូច្នេះបើមានសំណួរអ្វី ខ្ញុំត្រៀមលក្ខណៈដើម្បីឆ្លើយ ឬក៏ខ្ញុំខ្វះចន្លោះកន្លែងណា។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

អរគុណ។ សូមអញ្ជើញសហមេធាវីអន្តរជាតិនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី!

[១៥:២១:២៤]

**លោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

សូមអរគុណលោកប្រធាន។

ខ្ញុំនឹងចាប់ផ្ដើមដោយការពន្យល់អំពីគោលជំហរទូទៅ។ យើងជាដើមបណ្ដឹងរដ្ឋប្បវេណី យើងបានបង្ហាញជាច្រើនដងច្រើនសាមកហើយ គឺថាសូមឲ្យសវនាការឈានទៅមុខ ហើយយើងចង់ពិភាក្សានៅថ្ងៃនេះជាមួយភាគីអំពីបែបបទនៃការបន្តសវនាការទៅមុខទៀត ដើម្បីធ្វើយ៉ាងម៉េចឲ្យបានឆាប់រហ័ស។ អ្វីដែលសំខាន់ផងដែរនោះ គឺថាការលាតត្រដាងឲ្យឃើញការពិត។ ហើយយើងជឿជាក់ថា ការបង្ហាញឯកសារទាំងអស់ហ្នឹង គឺវាចូលរួមចំណែកក្នុងការលាតត្រដាងការពិត។ ដូច្នេះយើងមានផលប្រយោជន៍ផ្ទាល់។ ដូច្នេះឲ្យមានឯកសារច្រើនដែលត្រូវបង្ហាញនៅក្នុងសំណុំរឿង០០២/០២ នេះ។ ជាពិសេសដោយផ្អែកទៅលើភាពមិនច្បាស់លាស់ពាក់ព័ន្ធនឹងសំណុំរឿង០០៣, ០០៤ ដែលនៅក្នុងនោះដើមបណ្ដឹងរដ្ឋប្បវេណីរបស់យើងជាច្រើនបានដាក់ពាក្យសុំផងដែរ។ ដូច្នេះយើងមានការឯកភាពជាមួយ នឹងការបន្តបង្ហាញឯកសារបន្តទៅទៀតបែបនេះ។

យើងមានគោលជំហរដោយឡែក ពីព្រោះថាយើងគាំទ្រទៅដល់បណ្ដឹងអាជ្ញា។ យើងគាំទ្រឲ្យមានការចោទប្រកាន់ជនជាប់ចោទចំពោះបទឧក្រិដ្ឋដែលពួកគាត់ត្រូវជំនុំជម្រះ ក៏ប៉ុន្តែយើងធ្វើយ៉ាងណាគឺយើងត្រូវតែមានឯកភាព យើងជាមេធាវី យើងស្ថិតនៅក្នុងស្ថានភាពប្រហាក់ប្រហែលគ្នាទៅនឹងមេធាវីការពារក្ដីយើងយល់អំពីកង្វល់ដ៏ចម្បងរបស់ពួកគាត់នៅថ្ងៃនេះ។

[១៥:២៣:១២]

ខ្ញុំនឹងនិយាយអំពីប្រធានបទមួយចំនួនដែលត្រូវបានលើកឡើងដោយមេធាវីការពារក្ដី នួន ជា នៅក្នុងសំណើរបស់គាត់។ ដើម្បីឲ្យស្មោះត្រង់ជាមួយអង្គជំនុំជម្រះ យើងមិនមានលទ្ធភាពក្នុងការសិក្សានិងវិភាគឲ្យបានហ្មត់ចត់ទៅលើកំណត់ហេតុទាំងអស់ដែលបានផ្ដល់ជូនយើងខ្ញុំទេ។ នេះជាការពិត។ យើងមិនមានលទ្ធភាពសិក្សា និងវិភាគឲ្យបានពេញលេញ និងជាក់លាក់ទៅលើកំណត់ហេតុទាំងអស់នេះ ពីព្រោះថាលក្ខខណ្ឌដែលដាក់កំហិតដោយសហចៅក្រមស៊ើបអង្កេតនោះ គឺវាធ្វើឲ្យយើងមានការលំបាកក្នុងការគោរពតាម យើងពិបាកនឹងគោរពណាស់ គឺបើសិនជាយើងគោរពតាមលក្ខខណ្ឌនេះ យើងមិនអាចធ្វើការយើងឲ្យបានត្រឹមត្រូវទេ។ ខ្ញុំមិនដឹងថាតើការិយាល័យសហព្រះរាជអាជ្ញាកំពុងតែដាក់ -- ការិយាល័យសហចៅក្រមស៊ើបអង្កេតកំពុងតែស្ដាប់យើង ឬក៏អត់នោះទេ។ គឺពួកគាត់ គឺថាខ្ញុំសូមឲ្យមានការពង្រីកលក្ខខណ្ឌនៃការបង្ហាញឯកសារទាំងអស់ ពីព្រោះថាអ្វីដែលដាក់មកយើងនេះ គឺមិនអាចធ្វើបានទេ។ ខ្ញុំមានការភ្ញាក់ផ្អើលណាស់នៅពេលដែលថា គេមិនទុកចិត្តចំពោះមេធាវីរបស់យើងនេះ។ យើងមានកាតព្វកិច្ចបំពេញវិជ្ជាជីវៈរបស់យើង យើងមានកាតព្វកិច្ចក្នុងការគោរព យើងមានក្រម

សីលធម៌ក្នុងការគោរពការសម្ងាត់ យើងជាមេធាវី យើងមិនមែនជាក្មេងយូក្ខមនោះទេ។ ហើយបើគេប្រាប់យើងថាឯកសារហ្នឹងជាឯកសារសម្ងាត់ហើយ គឺយើងមានការទទួលខុសត្រូវណាស់។ ដូច្នេះយើងយើងមានការទទួលខុសត្រូវក្នុងការគោរពការសម្ងាត់ ហើយយើងឃើញហើយថាមានការចោទ -- ជនត្រូវចោទពីរដោយកំបាំងមុខ។ ចៅក្រមស៊ើបអង្កេតត្រូវតែធ្វើម៉េចឱ្យលក្ខខណ្ឌហ្នឹងមានភាពធូរស្រាលបន្តិចដើម្បីឱ្យយើងអាចធ្វើការរបស់យើងឱ្យបានត្រឹមត្រូវ។ ប្រសិនបើគេដកលក្ខខណ្ឌទាំងអស់នេះចេញ គឺយើងនឹងអាចមានការវិភាគបានស្រួល ហើយនៅពេលនោះគឺយើងនឹងអាចពិភាក្សាពីអ្វីដែលនឹងធ្វើបន្តទៀតនៅក្នុងសវនាការនេះ។ យើងត្រៀមខ្លួនរួចហើយ យើងបានប្រាប់អង្គជំនុំជម្រះកាលពីម្សិលមិញហើយថាយើងត្រៀមខ្លួននឹងស្តាប់សាក្សី 803 ហើយយើងក៏មិនជំទាស់ក្នុងការពន្យារការស្តាប់សក្ខីកម្មសាក្សី 803 ដែលបានលើកឡើងដោយមេធាវីការពារក្តីដែរ។ គឺធ្វើយ៉ាងម៉េចដើម្បីឱ្យយើងមានពេលវេលាគ្រប់គ្រាន់បន្ថែមដើម្បីឱ្យយើងអាចពិនិត្យមើលឯកសារបាន។ យើងមិនជំទាស់ទេក្នុងការពិភាក្សាទៅលើទំនប់១មករា នៅវគ្គបន្តមកទៀតនោះ។ ក៏ប៉ុន្តែសហព្រះរាជអាជ្ញាបានប្រាប់យើងហើយថាប្រហែលជាមិនមែនគំនិតល្អទេ។ យើងៗត្រូវការយ៉ាងម៉េចឱ្យមានព័ត៌មានឱ្យបានលម្អិតពាក់ព័ន្ធទៅនឹងដំណើរការនៃការបង្ហាញឯកសារទាំងអស់នុំង ដើម្បីឱ្យយើងអាចស្វែងរកដំណោះស្រាយបាន ធ្វើម៉េចឱ្យសវនាការយើងមានការវិវឌ្ឍទៅមុខលឿន។ ចំពោះយើងទោះជាយ៉ាងណាក៏ដោយ យើងចាំបាច់ត្រូវតែធ្វើយ៉ាងម៉េចឱ្យសវនាការទៅមុខបានឆាប់រហ័ស ហើយយើងជឿជាក់ទៅលើអង្គជំនុំជម្រះក្នុងការស្វែងរកដំណោះស្រាយសមស្រប ដើម្បីឱ្យសវនាការឈានទៅមុខដោយគោរពផងដែរនូវសិទ្ធិរបស់ភាគី។ យើងមានសំណើពីរពាក់ព័ន្ធទៅនឹងការបង្ហាញឯកសារនេះ គឺថាធ្វើយ៉ាងម៉េចឱ្យយើងទទួលបានព័ត៌មានជាក់លាក់អំពីដំណើរការនៃការស៊ើបអង្កេតដើម្បីឱ្យយើងដឹងថាតើមានភស្តុតាងថ្មីអ្វីខ្លះដែលនឹងអាចកើតមានឡើង ជាពិសេសពាក់ព័ន្ធទៅនឹងផ្នែកដែលយើងកំពុងតែសិក្សាទាំងអស់គ្នានេះ។ ដូច្នេះ សំណើរបស់យើងបានធ្វើដោយសហមេធាវីការពារក្តីរួចទៅហើយ។ គឺថាធ្វើយ៉ាងម៉េចឱ្យមានការជូនដំណឹងឱ្យបានពេញលេញ។ ដូច្នេះ ធ្វើយ៉ាងម៉េចដើម្បីឱ្យលោក លោកស្រីចៅក្រម គឺថាដើម្បីឱ្យយើងទាំងអស់គ្នាដើម្បីឱ្យអង្គជំនុំជម្រះមានតួនាទីកាន់តែធំ នៅក្នុងការគ្រប់គ្រងដំណើរការនៃការសវនាការរបស់យើងនេះ។ បន្ទាប់មកទៀត ខ្ញុំនឹងឆ្លើយតបមួយចំណុចម្តងៗ ទៅនឹងការដាក់ឯកសាររបស់ខាងមេធាវី នួន ជា ដើម្បីជៀសវាងនូវការផ្តល់ចម្លើយជាលាយលក្ខណ៍អក្សរ។ ខ្ញុំសូមពិភាក្សាដោយខ្លីទៅលើបញ្ហាខ្មែរក្រោម។

[១៥:២៧:៤៤]

ខ្ញុំសារភាពថា ខ្ញុំពិបាកយល់អំពីគោលជំហររបស់មេធាវីការពារក្ដី នួន ជា ពាក់ព័ន្ធនឹងចំណុចនេះ។ ដូចដែលយើងខ្ញុំបានបង្ហាញរួចមកហើយ អង្គជំនុំជម្រះទទួលអង្គហេតុដែលមានដាក់នៅក្នុងឧបសម្ព័ន្ធនៃសេចក្ដីសម្រេចទី២ ពាក់ព័ន្ធនឹងការបំបែកនីតិវិធីដែលបានកំណត់ពីប៉ារ៉ាម៉ែតនៃការជំនុំជម្រះក្ដីនេះ។ ឧបសម្ព័ន្ធនេះ គឺឯកសារ E301/9/1.1។ ឧបសម្ព័ន្ធនេះរៀបរាប់អំពីកថាខណ្ឌនៃដីកាដំណោះស្រាយ ដែលអង្គជំនុំជម្រះត្រូវសម្រេច។ នៅក្នុងកថាខណ្ឌ៣២០ នៃដីកាដំណោះស្រាយដែលនិយាយអំពីត្រាំកក់ និង ការកំណត់គោលដៅជាក់លាក់ទៅលើក្រុមមួយចំនួននោះ មាននិយាយអំពីខ្មែរក្រោមយ៉ាងច្បាស់។ ដូច្នេះ អង្គជំនុំជម្រះទទួលបណ្ដឹងពាក់ព័ន្ធនឹងការប្រព្រឹត្តទៅលើខ្មែរក្រោមនៅក្នុងសហករណ៍ត្រាំកក់។ ប្រសិនបើអង្គជំនុំជម្រះយល់ថាខ្លួនមិនទទួលបណ្ដឹងពាក់ព័ន្ធទៅនឹងចំណុចនេះ នេះគឺជាយុត្តិនិសេធហើយ។ ហើយនេះគឺជាមូលហេតុនៃការប្ដឹងសាទុក្ខ។ ហើយយើងៗគាំទ្រដោយស្ម័គ្រចិត្តចំពោះបញ្ហានេះ។ អង្គជំនុំជម្រះទទួលអង្គហេតុ។ ដូច្នេះ ភស្ដុតាងពាក់ព័ន្ធទៅនឹងអង្គហេតុទាំងអស់នេះត្រូវតែមានការសិក្សាដោយអង្គជំនុំជម្រះ។ ពាក់ព័ន្ធទៅនឹងការកំណត់ប្រភេទនៃបទល្មើស គឺអង្គជំនុំជម្រះជាអ្នកកំណត់ខ្លួនឯង ហើយនិងភាគីជាអ្នកផ្ដល់ទឡ្ហីករណ៍ដើម្បីឲ្យដឹងថាតើឧក្រិដ្ឋកម្មណាមួយ ត្រូវបានទទួលយកបែបនេះនោះ។ យើងមានយោបល់ថា អង្គជំនុំជម្រះគួរតែផ្ដោតទៅលើឧក្រិដ្ឋកម្មនៃការធ្វើទុក្ខបុកម្នេញដើម្បីឲ្យដឹងថា ការប្រព្រឹត្តចំពោះខ្មែរក្រោមនៅក្នុងសហករណ៍ត្រាំកក់នឹងត្រូវចាត់ទុកថាជាឧក្រិដ្ឋកម្មធ្វើទុក្ខបុកម្នេញ ឬក៏អត់? ជាថ្មីម្ដងទៀត អង្គជំនុំជម្រះមិនមានជម្រើសទេ មិនមែនជាជម្រើសរបស់សហព្រះរាជអាជ្ញាទេ។ អង្គជំនុំជម្រះទទួលបណ្ដឹង។ ដូច្នេះ អង្គជំនុំជម្រះត្រូវតែ ពិនិត្យទៅលើបញ្ហាខ្មែរក្រោមនេះ ក្នុងសំណុំរឿង០០២/០២។ ដូច្នេះអង្គជំនុំជម្រះមិនអាចធ្វើអ្វីផ្សេងពីនេះទេ។

[១៥:៣០:១០]

ជាចុងក្រោយ ខ្ញុំសូមនិយាយអំពីកំណត់ហេតុស្ដាប់ចម្លើយដែលបានដាក់តាមរយៈដំណើរការនៃការបង្ហាញឯកសារ។ មេធាវីការពារក្ដី នួន ជា ហាក់ដូចជាព្រួយបារម្ភអំពីជោគវាសនានៃកំណត់ហេតុទាំងអស់នេះ។ ចំពោះយើង យើងច្បាស់ណាស់ថា ចាប់ពីពេលដែលកំណត់ហេតុទាំងអស់នេះ ត្រូវបានដាក់ចូលនៅក្នុងកិច្ចពិភាក្សាដេញដោលរបស់យើងនៅក្នុងសំណុំរឿង ០០២/០២ ឯកសារទាំងអស់នេះក្លាយទៅជាភស្ដុតាងនៃសំណុំរឿង ០០២/០២ ។ ដូច្នេះ ប្រសិនបើដាក់ចូលទៅក្នុងសំណុំរឿងយើង ត្រឹមត្រូវតាមវិធានហ្នឹងហើយ យើងអាចប្រើប្រាស់ឯកសារទាំងអស់នេះបាន ដើម្បីយកមកពិភាក្សាដេញ

ដោលគ្នា។ ដូច្នេះយើងមិនថាំ -- យើងដូចគ្មានអ្វីត្រូវចោទសួរអំពីជោគវាសនានៃកំណត់ហេតុទាំងអស់នេះទេ។ ចាប់ពីពេលដាក់ចូលនៅក្នុងសំណុំរឿងហើយ វាជាឯកសារនៃសំណុំរឿងហើយ។ ដូច្នេះ យើងទាំងអស់គ្នា អាចប្រើឯកសារទាំងអស់នេះបាន។ ហើយអង្គជំនុំជម្រះ ក៏អាចប្រើឯកសារនេះដើម្បីធ្វើការពិភាក្សាសម្រេចដែរ។ ចំពោះយើង គឺយើងគ្មានសង្ស័យអ្វីទេ។

ឥឡូវនេះខ្ញុំចង់ឆ្លើយតប ឬក៏ផ្តល់នូវចម្លើយរបស់យើងទៅនឹងការព្រួយបារម្ភរបស់មេធាវីការពារក្តីពាក់ព័ន្ធនឹងបញ្ហាធនធានមនុស្ស ហើយនិងលទ្ធភាពរបស់ភាគីផ្សេងៗក្នុងការធ្វើបំពេញភារកិច្ចផ្សេងៗជាពិសេសការវិភាគទៅលើឯកសារនៃសំណុំរឿងយើងនេះ។ ខ្ញុំសូមរំឭកជូនអង្គជំនុំជម្រះ កុំ -- ខ្ញុំដឹងហើយថាអង្គជំនុំជម្រះដឹង ក៏ប៉ុន្តែភាគី គឺភាគីខាងក្រៅនៃសវនាការនេះគួរតែដឹងផងដែរ។ ដូច្នេះហើយខ្ញុំត្រូវតែរំឭក។ យើងជាសហមេធាវីនាំមុខដោយមានជំនួយ អំពីមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីយើងមានភារកិច្ចច្រើនណាស់។ យើងមានការពិគ្រោះយោបល់ជាមួយដើមបណ្តឹងរដ្ឋប្បវេណី។ យើងគ្រប់គ្រងដើមបណ្តឹងរដ្ឋប្បវេណីជាង៣០០០នាក់ ដូច្នេះយើងត្រូវតែពិគ្រោះយោបល់ជាមួយពួកគាត់។ ដូច្នេះនេះជាចំណុចសំខាន់ណាស់។ ការត្រៀមរៀបចំសវនាការ គឺជាការងារ៥៥ -- ៥០ភាគរយនៃការងាររបស់យើង។ ដូច្នេះ យើងខ្លួនឯងផ្ទាល់នោះ ក៏ពាក់ព័ន្ធទៅនឹងទំហំការងារដែលបង្កើតឡើងដោយសវនាការនេះដែរ។

[១៥:៣២:៤០]

ជាមួយនឹងលក្ខខណ្ឌរឹតត្បិតពាក់ព័ន្ធទៅនឹងការវិភាគទៅលើឯកសារ ដែលបានបង្ហាញដោយសហចៅក្រមស៊ើបអង្កេតនោះ គឺថាយើងពិបាកនឹងការធ្វើការនេះណាស់ ព្រោះថាយើងមិនអាចពឹងកម្មសិក្សាការីយើងឲ្យធ្វើការនេះបានទេ គឺថាមានការរឹតត្បិត បើសិនជាយើងមានបន្ធូរបន្ថយលក្ខខណ្ឌទាំងអស់ហ្នឹង គឺថាយើងសង្ឃឹមថាយើងនឹងអាចគ្រប់គ្រងនូវភារកិច្ចរបស់យើងបាន ដើម្បីឲ្យសវនាការយើងវិវត្តន៍ទៅមុខបានឆាប់រហ័ស។ ខ្ញុំគិតថា ខ្ញុំសូមបញ្ចប់ត្រឹមនេះ ហើយខ្ញុំគិតថាខ្ញុំបានឆ្លើយតបទៅនឹងសំណើរបស់មេធាវីការពារក្តីលោក នួន ជា ហើយ។ សូមអរគុណលោកប្រធាន។

**ប្រធានអង្គប្រជុំ៖**

បាទអរគុណ។ ហើយនៅមុនពេលដែលអង្គជំនុំជម្រះ ប្រគល់វេទិកាជូនភាគីសហព្រះរាជអាជ្ញា និងសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីនោះ ចៅក្រម ក្លូឌា ហ្វេនស៍ បានសួរទៅក្រុមមេធាវីការពារក្តីថា តើទំនងជាត្រូវការពេលវេលាយ៉ាងម៉េចទៅ នៅក្នុងការដែលពិនិត្យមើលឯកសារ

ដែលដាក់ថ្មីៗនេះ ដើម្បីមានលទ្ធភាពចូលរួមសវនាការ ឬក៏មានមតិយោបល់យ៉ាងម៉េចទៅពាក់ព័ន្ធជាមួយនឹងការរៀបចំពេលវេលានៅក្នុងដំណើរការសវនាការនាពេលអនាគត។

បើមានសូមអញ្ជើញ! សូមអញ្ជើញលោកស្រីចៅក្រម ក្លូឌា ហ្វេនស៍ បញ្ជាក់បន្ថែមទៀត។

[១៥:៣៤:០៨]

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

ខ្ញុំគិតថាច្បាស់លាស់ហើយ ប៉ុន្តែខ្ញុំមានសំណួរបន្ថែម ពាក់ព័ន្ធទៅនឹងមេធាវីការពារក្តីដែលអាចឆ្លើយតបមកខ្ញុំបាន។ ចំណុចនេះគឺពាក់ព័ន្ធទៅនឹងសំណើសុំផ្អាកសាក្សីមួយចំនួន ដែលលោកបានបញ្ជាក់ជាពិសេសថា 803 និង 809។ ខ្ញុំសូមសង្ខេបនូវអ្វីដែលលោកបានលើកឡើង។

យើងមានការស៊ើបអង្កេតនៅក្នុងរឿង០០៣, ០០៤ ហើយយើងមិនដឹងថាពេលណាបញ្ចប់នោះទេ។ ហើយយើងបានស្តាប់ថាការបង្ហាញឯកសារដែលត្រូវបានស៊ើបអង្កេតនេះ នឹងបន្តទៅមុខទៀត។ ហើយយើងមិនអាចទាយស្មានឲ្យដឹង ថាតើផ្នែកណាមួយ ឬក៏ចំណុចណាមួយក្នុងសវនាការនាពេលបច្ចុប្បន្នហ្នឹងអាចទទួលរងផលប៉ះពាល់។ ព្រះរាជអាជ្ញាបានប្រាប់យើងរួចទៅហើយថាខាងព្រះរាជអាជ្ញាក៏មិនអាចកំណត់បានថាៗ តើផ្នែកណាមួយនៃដីៗកាដំណោះស្រាយមិនអាចប៉ះពាល់ដោយការបង្ហាញឯកសារនេះឡើយ។ ដូច្នេះ និយាយដោយសង្ខេបទៅ ខ្ញុំគិតថានៅពេលនេះ ការផ្អាកសវនាការដែលរង់ចាំការស៊ើបអង្កេតសំណុំរឿង០០៣, ០០៤ មិនមែនជាជម្រើសនោះទេ។ ដូច្នេះ ក្នុងពេលឥឡូវនេះ តើលោកនៅតែបន្តផ្អាកកោះហៅសាក្សីដែលមានឋានៈខ្ពស់នៅក្នុងកម្មាភិបាលដែរ ឬមួយក៏យ៉ាងណាដែរ?

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំគិតថានេះគឺជាសំណួរដ៏ល្អ។ ហើយខ្ញុំក៏មិនដឹងថាតើខ្ញុំអាចឆ្លើយបាន ឬមិនបាននៅពេលឥឡូវនេះឡើយ។ អ្វីដែលខ្ញុំដឹងច្បាស់ គឺថាយើងនឹងមានឱកាសបន្តទៅមុខមួយរយៈទាក់ទងទៅនឹងត្រាំកក់ ហើយនិងក្រាំងតាចាន់។ ហើយយើងនៅមានសាក្សីខ្លះទៀតដែលយើងអាចបន្តទៅមុខ ហើយអាចនឹងមានសវនាការនៅលើឯកសារ ព្រមទាំងសវនាការទៅលើ -- ព្រមទាំងសាក្សីទៅលើទីតាំងឧក្រិដ្ឋកម្ម។ ដូច្នេះ ខ្ញុំគិតថាវាមិនចាំបាច់ត្រូវបញ្ឈប់ភ្លាមៗនោះទេ។

[១៥:៣៦:២៦]

ប៉ុន្តែ ទោះយ៉ាងណាក៏ដោយ យើងនៅមានបញ្ហាដូចដែលលោកស្រីចៅក្រមបានបញ្ជាក់រួចទៅហើយ គឺថានៅពេលផ្នែកបន្ទាប់ណាដែលយើងត្រូវធ្វើ គឺវាអាចប៉ះពាល់។ ដូច្នេះខ្ញុំគិតថាដំណោះស្រាយ

មួយ គឺថាយើងមានកិច្ចប្រជុំរៀបចំសវនាការនៅពេលបន្ទាប់ ដែលអញ្ជើញសហចៅក្រមស៊ើបអង្កេតអន្តរជាតិ ហើយបង្ហាញគាត់អំពីបញ្ហាយើង ហើយសួរទៅគាត់ថាតើទីតាំងឧក្រិដ្ឋកម្មណាមួយដែលលោកគិតថាមានផលប៉ះពាល់តិចបំផុត ឬក៏មានផលប៉ះពាល់ជាអប្បបរិមាចំពោះការជំនុំជម្រះ។ ខ្ញុំយល់ស្របជាមួយនឹងខាងព្រះរាជអាជ្ញា ដែលព្រះរាជអាជ្ញាគាត់និយាយថា មន្ទីរសន្តិសុខនៅជិតភូមិភាគឧត្តរ ក៏ដូចជាទំនប់១មករា វាកំពុងតែស៊ើបអង្កេត។ ដូច្នេះ យើងមិនគួរបន្តទៅលើចំណុចទាំងអស់ហ្នឹងទេ។ ខ្ញុំយល់ស្រប ហើយយើងក៏ដឹងអំពីបញ្ហាទាំងអស់នេះដែរ។ ដូច្នេះ ខ្ញុំគិតថាឥឡូវនេះ វាពិបាកណាស់សម្រាប់ក្រុមយើងខ្ញុំក្នុងការនិយាយថា តើយើងយ៉ាងម៉េចអីយ៉ាងម៉េចនោះ។ ដូច្នេះ ខ្ញុំមិនប្រាកដថាតើយើងដោះស្រាយជាមួយបញ្ហាទាំងអស់នេះបានដោយរបៀបណា។

[១៥:៣៧:៣៩]

ពាក់ព័ន្ធទៅនឹងសំណួរទី១ ខ្ញុំចាំថាអង្គជំនុំជម្រះខ្លួនឯងកាលពីខែតុលាឆ្នាំទៅ ក៏បានផ្អាកការសវនាការដំបូងអស់រយៈពេលមួយសប្តាហ៍ ដោយសារតែនៅពេលហ្នឹង គឺយើងទទួលបានឯកសារមួយប្រហែលជា៥០០ទំព័រ។ ខ្ញុំគិតថាអង្គជំនុំជម្រះក៏ដូចខ្ញុំដែរ យើងមិនអាចអានឲ្យបានលឿនហួសពីល្បឿនដែលយើងធ្វើនោះឡើយ។ ប៉ុន្តែ ជាគោលការណ៍ណែនាំ ខ្ញុំគិតថា ៣០០ទំព័រ -- ៣០០០ទំព័រ ប្រហែលជាត្រូវការ៦សប្តាហ៍។ ខ្ញុំគិតថា អ្វីដែលយើងនិយាយនេះ អាចដោះស្រាយបញ្ហាបាន។ ដូច្នេះ ខ្ញុំគិតថានៅពេលដែល -- ដូច្នេះខ្ញុំគិតថា ហេតុអ្វីក៏យើងមិនអញ្ជើញចៅក្រម ហាម៉ុន មកទីនេះ ហើយនឹងសួរគាត់ថា តើគាត់ស្នើថាយើងគួរធ្វើអ្វី? ប្រសិនបើមិនដូច្នេះទេ ខ្ញុំគិតថា ដូចជាគ្មានបញ្ហាអ្វីចំពោះដំណោះស្រាយនេះឡើយ។

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

ខ្ញុំមិនមែនស្នើសុំឲ្យលោកផ្តល់យោបល់មកយើងពីដំណោះស្រាយទេ គ្រាន់តែចង់ឲ្យលោកបញ្ជាក់បំភ្លឺតែប៉ុណ្ណោះ។ ចំពោះប្រតិកម្មដំបូងដែលថាអញ្ជើញឲ្យចៅក្រមស៊ើបមកនេះ គាត់ក៏អត់ដឹងដែរ គាត់ក៏មិនប្រាកដថាអំពីអ្វីដែលនឹងបន្តទៅមុខដែរ។

[១៥:៣៨:១០]

**លោក វិចទ័រ កូប៉េ៖**

អាចថា គាត់និយាយថា វាមានភាពពាក់ព័ន្ធមួយចំណុច ប៉ុន្តែគាត់អាចដឹងថាតើមន្ទីរសន្តិសុខណាដែលគាត់កំពុងស៊ើបអង្កេត។ ខ្ញុំមិនមែនសួរអំពីព័ត៌មានលម្អិតថាមានអ្វីកើតឡើងនៅក្នុងការស៊ើប

អង្កេតនោះទេ។ ប៉ុន្តែ អាចថាអូរកន្សែងជាផ្នែកនៃការស៊ើបអង្កេត។ ដូច្នេះ ប្រសិនបើគាត់និយាយអ៊ីចឹង យើងហេតុអីទៅធ្វើទៅលើចំណុចទាំងអស់នោះ។ ប៉ុន្តែ ប្រសិនបើគាត់និយាយថាគាត់ស៊ើបអង្កេតចប់ហើយ គាត់អាចបង្ហាញនូវកំណត់ហេតុសរុបចម្លើយដែលពាក់ព័ន្ធ ខ្ញុំមិនដឹងថាយ៉ាងម៉េចនោះទេ។ ខ្ញុំគិតថានៅក្នុងភាសាហូឡង់ គឺយើងមានសុភាសិតមួយ "ប្រសិនបើទឹកកំពុងតែហូរ ហេតុអីក៏យើងចាំបាច់ទៅជូតសម្អាតធ្វើអី ទុកឲ្យទឹកហូរអស់សិនទៅ សឹមយើងជូតសម្អាតតាមក្រោយ"។ ដូច្នេះ ខ្ញុំគិតថា ខ្ញុំអាចឆ្លើយជាមួយសំណួរលោកស្រីចៅក្រមបាន។

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

អ៊ីចឹងលោកស្នើសុំពេលតែ៦សប្តាហ៍ទេ។ អ៊ីចឹងគ្រប់គ្រាន់ទេ?

**លោក វ៉ិចទ័រ កូប៉េះ៖**

ខ្ញុំផ្អែកទៅលើអ្វីដែលលោក លោកស្រីចៅក្រម សម្រេចទៅលើចំនួនទំព័រ ៥០០ទំព័រនោះកាលពីឆ្នាំទៅ។

**ប្រធានអង្គជំនុំ៖**

បាទ សូមអញ្ជើញលោកមេធាវី គង់ សំអុន!

[១៥:៤០:២៨]

**លោក គង់ សំអុន៖**

បាទសូមអរគុណលោកប្រធាន។ ខ្ញុំសូមឆ្លើយតបទៅនឹងសំណួររបស់លោកចៅក្រម លោកស្រីចៅក្រម ហ្វេនស៍។ ទាក់ទងទៅនឹងចំណុចមួយដែលថា យើងគួររង់ចាំការស៊ើបអង្កេតឲ្យបានចប់ ឬមួយក៏រៀបចំសវនាការនេះ។ ខ្ញុំយល់ថា សម្រាប់នីតិវិធីរបស់យើងនៅក្នុងរឿង០០២ គឺបានបញ្ចប់នីតិវិធីស៊ើបអង្កេតតាំងពីឆ្នាំ២០១០រួចមកហើយ។ ដូច្នេះ ឯកសារទាំងឡាយដែលដាក់បញ្ចូលបន្ថែមដែលមានសហចៅក្រមអន្តរជាតិ -- សូមទោស សហចៅក្រមស៊ើបអង្កេតអន្តរជាតិដែលធ្វើការស៊ើបអង្កេតបន្ថែមទៅលើសំណុំរឿងផ្សេងទៀតនោះ វាជាការដាក់បន្ថែមតាមការយល់ឃើញរបស់តំណាងសហព្រះរាជអាជ្ញាដែលយល់ថាមានប្រយោជន៍សម្រាប់ការចោទប្រកាន់ ឬក៏សម្រាប់នៅក្នុងរឿងក្តីនៃសំណុំរឿង ០០២នេះ។ ដូច្នេះ យើងមិនមានចេតនាណាមួយចង់រង់ចាំ ឬក៏ធ្វើឲ្យពន្យារយឺតយូរនូវការសវនាការក្នុងសំណុំរឿង០០២នេះទេ។ ប៉ុន្តែបើសិនជាយើងកំពុងតែធ្វើការជំនុំជម្រះទៅលើសំណុំរឿង០០២ ដល់វគ្គពីរនេះទៅហើយ ហើយដែលមានអង្គហេតុមួយចំនួនដែលយើងត្រូវធ្វើការពិភាក្សា ព្រោះថាសវនាការវា

ត្រូវធ្វើជាសាធារណៈ ប៉ុន្តែមិនអាចធ្វើការដេញដោលគ្នាបានជាសាធារណៈ ដោយសារតែសហចៅក្រមអន្តរជាតិ សហចៅក្រមស៊ើបអង្កេតអន្តរជាតិកំពុងតែធ្វើការស៊ើបអង្កេតទៅលើអង្គហេតុមួយចំនួននោះ អានេះវាជារឿងដោយឡែក ខ្ញុំយល់ថាវាមិនគួរជាប់ពាក់ព័ន្ធគ្នា មិនគួរជាការរំខានទៅដល់ការសួរដេញដោលនៅក្នុងសំណុំរឿងរបស់យើងទេ។

[១៥:៤២:១៧]

ដោយឡែកចំពោះពេលវេលា យើងក៏មិនមានភាពច្បាស់លាស់ទៅលើថា តើរយៈពេលប៉ុនណាដែលយើងត្រូវធ្វើការសិក្សាចំណាយទៅលើការពិនិត្យទៅលើឯកសារទាំង១៦ក្រុណ្ឌធំនេះដែរ។ ក៏ប៉ុន្តែយើងអាចសន្និដ្ឋានជាលក្ខណៈរួមថា ប្រហែលជាយ៉ាងតិចណាស់ក៏ត្រឹម៦សប្តាហ៍ដែរ ដែលយើងអាចពិនិត្យទៅលើអង្គហេតុ និងភាពពាក់ព័ន្ធមួយចំនួនទៅលើឯកសារទាំងអស់នោះ។ ដូច្នេះយើងយល់ថាសម្រាប់៦សប្តាហ៍នេះ មិនមានន័យថា លោកអង្គជំនុំជម្រះបន្តសវនាការ ឬក៏ធ្វើការដេញដោល ឬក៏ត្រូវរៀបចំជាញត្តិអីផ្សេងៗទៀត ដែលធ្វើឲ្យមានប៉ះបាល់ដល់ពេលវេលារបស់យើងទេ។ បានន័យថាជារយៈពេលមួយដែលត្រូវផ្តល់ឲ្យយើងក្នុងការពិនិត្យទៅលើឯកាសរនោះទាំងស្រុង។

បើក្នុងករណីដែលអង្គជំនុំជម្រះបន្តធ្វើសវនាការផង ដោយផ្តល់ពេលវេលាផងនោះ នោះវាធ្វើឲ្យយើងប៉ះពាល់ដល់ពេលវេលានៃការពិនិត្យទៅលើឯកសារទាំងអស់នោះហើយ។

មុននេះអំមិញ សហមេធាវីនាំមុខអន្តរជាតិ -- នាំមុខដើមបណ្តឹងរដ្ឋប្បវេណីអន្តរជាតិបានមានប្រសាសន៍អំពីរយៈពេលនៃការធ្វើការងាររបស់ខ្លួនថា ចំណាយពេល៥០ភាគរយនៅក្នុងការចូលរួមសវ-នាការនេះ។ សម្រាប់យើង ក្នុងពេលបច្ចុប្បន្ននេះ យើងយល់ថា គឺ១០០ភាគរយហើយ ដែលយើងត្រូវចំណាយទៅលើការធ្វើ ការចូលរួមសវនាការនេះ ពីព្រោះក្នុង១សប្តាហ៍ យើងត្រូវចំណាយពេល៤ថ្ងៃទៅហើយចូលរួមក្នុងសវនាការ។ ហើយយើងពេលតិចតួចបំផុតសម្រាប់ក្នុងការរៀបចំសវនាការ រៀបចំមើលពិនិត្យឯកសារទាំងឡាយដែលជាប់ពាក់ព័ន្ធសវនាការនេះ។ ដូច្នេះវាមានន័យថា យើងមិនអាចមានពេលវេលាផ្សេងទៀតដើម្បីចំណាយទៅលើការពិនិត្យឯកសារទេ បើសិនជាអង្គជំនុំជម្រះមិនបានផ្តល់ពេលវេលាគ្រប់គ្រាន់សមរម្យនោះ។ បាទ សូមអរគុណ។

[១៥:៤៤:៤២]

**លោក វ៉ិចទ័រ កូប៉េ៖**

លោកប្រធាន ប្រសិនបើជាអនុញ្ញាត ខ្ញុំចង់លើកបន្តិចអំពីបញ្ហាខ្មែរក្រោម។ តាមដែលខ្ញុំដឹង គឺ

តាមពាក្យរបស់មេធាវីដើមបណ្ដឹងរដ្ឋប្បវេណី គឺគាត់មកពីប្រព័ន្ធប្រទេសបារាំង។ ប្រសិនបើខ្ញុំយល់មិនខុសទេ គឺថាតាមអ្វីដែលគាត់និយាយចំពោះអង្គជំនុំជម្រះ គឺថាមានម្ដងនោះ គេចោទប្រកាន់ -- គឺផ្ដន្ទាទោស នួន ជា អាចពីបទប្រល័យពូជសាសន៍ទៅលើខ្មែរក្រោម ឬក៏ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិតាមរយៈការសម្លាប់ ឬក៏សម្លាប់រង្គាល ឬក៏និយាយម្យ៉ាងទៀត តាមដែលខ្ញុំយល់ នៅពេលដែលខ្ញុំជជែកជាមួយកូនក្ដី -- ខ្ញុំនឹងជជែកជាមួយកូនក្ដីខ្ញុំនៅថ្ងៃស្អែក ខ្ញុំត្រូវប្រាប់ថាអាចមានលទ្ធភាព ឬក៏មិនមានលទ្ធភាព។ នេះជាអ្វីដែលខ្ញុំចង់ដឹង។ ថាតើតាមនីតិវិធីរបស់បារាំង ថាតើអាចផ្ដន្ទាទោសកូនក្ដីខ្ញុំចំពោះឧក្រិដ្ឋកម្មអន្តរជាតិ ពាក់ព័ន្ធទៅនឹងក្រុមខ្មែរក្រោមបានដែរឬទេ ខ្ញុំអត់ដឹងទេ។ ខ្ញុំស្នើសុំឲ្យមានការបញ្ជាក់បំភ្លឺ។ ហើយខ្ញុំគិតថាកូនក្ដីសមនឹងទទួលបានការបញ្ជាក់បំភ្លឺបែបនេះ។ ហើយខ្ញុំក៏មិនបានឮខាងព្រះរាជអាជ្ញាមានផ្ដល់ប្រតិកម្មអ្វីទាក់ទងទៅនឹងអ្នកនាំពាក្យផ្លូវការរបស់តុលាការនោះឡើយ។ ដូច្នេះ ខ្ញុំគិតថាលោក អលសិន មិនបាននិយាយអ្វីដោយខ្លួននោះទេ គឺថាគេបង្គាប់ ឬក៏គេណែនាំឲ្យគាត់និយាយ។

ដូច្នេះ អានេះ អ្វីដែលខ្ញុំយល់អំពីនីតិវិធី ក៏ដូចជាបញ្ហាដែលកើតឡើងនៅក្នុងឆ្នាំ២០១០។ ប្រសិនបើយើងយល់ខុស សូមជម្រាបមកយើងខ្ញុំផង ហើយយើងខ្ញុំនឹងគិតអំពីមធ្យោបាយណាមួយ ឬក៏យុត្តិ-សាស្ត្រណាមួយដើម្បីធ្វើ ប៉ុន្តែនិយាយតាមត្រង់ទៅ ក្នុងពេលឥឡូវហ្នឹង ខ្ញុំអត់ដឹងទេ ខ្ញុំថាវាអាចមានលទ្ធភាព។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញសហព្រះរាជអាជ្ញាអន្តរជាតិ!

[១៥:៤៧:០៨]

**លោក នីកូឡាស គូមជែន៖**

ខ្ញុំសូមឆ្លើយតបដោយបន្តិច គឺថាលោក អលសិន ជានាំពាក្យរបស់តុលាការ មិនមែនអ្នកនាំពាក្យរបស់រដ្ឋព្រះរាជអាជ្ញាទេ។ យើងក៏មិនមែនជាអ្នកផ្ដល់ទៅព័ត៌មានទៅគាត់ ឬក៏ប្រាប់គាត់ឲ្យនិយាយអ្វីឡើយ។ ដូច្នេះ ការគ្រាន់តែការដកស្រង់ពាក្យរបស់លោក អលសិន គឺជារឿងឥតប្រយោជន៍ ហេតុដូច្នេះហើយ ទើបខាងព្រះរាជអាជ្ញាមិនបានឆ្លើយតប ហើយយើងគិតថា វាគ្មានប្រយោជន៍អីទេ។

ខ្ញុំចង់ឆ្លើយតបទៅនឹងបញ្ហានៃការពន្យារពេលដែលមេធាវីការពារក្ដីស្នើសុំ។ នៅក្នុងការពិភាក្សាក្នុងពេលរសៀលនោះ គឺយើងច្បាស់ហើយថា វាជាដំណើរការដែលកំពុងតែបន្តទៅមុខ ហើយវានឹងបន្តទៅមុខទៀត។

[១៥:៤៧:៤៣]

មេធាវីការពារក្តីស្នើសុំឲ្យមានការផ្អាកសវនាការ ដែលខ្ញុំគិតថាវានឹងបង្កើតឲ្យមានជាយុត្តិសាស្ត្រដ៏អាក្រក់បំផុត។ មេធាវីការពារក្តីអាចបែងចែកកំណត់ហេតុស្តាប់ចម្លើយនៅក្នុងក្រុមការងារ ក៏ដូចជាក្នុងបុគ្គលិករបស់គាត់ ហើយបុគ្គលិករបស់គាត់ គាត់អាចអាន។ ហើយខ្ញុំគិតថា ពួកគេអាចមានកម្មសិក្សាការី ហើយក៏មានបុគ្គលិកដែរ ដែលពួកគេអាចបែងចែកការងារនៅក្នុងចំណោមបុគ្គលិករបស់គេ។ ទោះបីថាពួកគាត់មិនអាចទទួលបានកំណត់ហេតុស្តាប់ឆ្លើយសម្រាប់សាក្សីនៅពេលបន្ទាប់ទៀតក៏ដោយ ក៏ខ្ញុំគិតថា ប្រសិនបើពួកគេគិតថាឯកសារនេះ គឺមានផលប៉ះពាល់ចំពោះការសួរសំណួរ ពួកគេអាចនឹងធ្វើការសួរនៅក្នុង០០៣, ០០៤ ព្រោះថាទាំងអស់គឺវាមានផលប៉ះពាល់ចំពោះសវនាការ។ អ៊ីចឹងគេអាចធ្វើញត្តិនៅពេលបន្ទាប់ ដើម្បីស្នើសុំកោះហៅសាក្សីនោះមកសាជាថ្មី។ នេះគឺជាវិធីសាស្ត្រដែលយើងអាចដោះស្រាយបញ្ហាបាន ព្រោះថាការបង្ហាញឯកសារនៅតែបន្តទៅមុខទៀត។ យើងមិនអាចផ្អាកសវនាការ ហើយយើងក៏មិនអាចផ្អាកបង្ហាញឯកសារនេះបានដែរ។ ដូច្នេះហើយ ប្រសិនបើអ្វីដែលអាចធ្វើបាន គឺថាយើងគ្រាន់តែផ្តល់ឯកសារ។ ដូច្នេះខ្ញុំស្នើសុំដល់លោក លោកស្រីចៅក្រម មេត្តាបន្តសវនាការទៅមុខដោយមិនផ្អាក។

**ប្រធានអង្គជំនុំ៖**

អរគុណ។ សូមអញ្ជើញ!

[១៥:៤៩:២១]

**លោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

សូមអរគុណលោកប្រធាន។ ខ្ញុំសូមឆ្លើយតបទៅនឹងការលើកឡើងដោយលោកមេធាវី កូប៉េ ពាក់ព័ន្ធនឹងខ្មែរក្រោម។ គាត់ប្រើប្រាស់ពាក្យ "ប្រល័យពូជសាសន៍" ខ្ញុំមិនបានប្រើពាក្យហ្នឹងទេ។ ប្រហែលជា ការសម្តីរបស់ខ្ញុំបកប្រែមិនត្រូវ ឬក៏យ៉ាងម៉េច។ គាត់ប្រើពាក្យ "ប្រល័យពូជសាសន៍"នេះ។ ខ្ញុំៗអត់បាននិយាយអ៊ីចឹងទេ ខ្ញុំនិយាយថាអង្គជំនុំជម្រះទទួលបណ្តឹងពាក់ព័ន្ធទៅនឹងខ្មែរក្រោមនៅត្រាំកក់។ ហើយអង្គជំនុំជម្រះត្រូវសម្រេចអំពីការកំណត់ប្រភេទបទល្មើសពាក់ព័ន្ធនឹងចំណុចនេះ។ ប្រសិនបើបានកំណត់ហើយនោះ គឺថាវាមានឧក្រិដ្ឋកម្មដែលពាក់ព័ន្ធទៅនឹងត្រាំកក់ ឧទាហរណ៍ដូចជាឧក្រិដ្ឋកម្មធ្វើទុក្ខបុកម្នេញ។ យើងបានស្តាប់ខ្មែរក្រោមម្នាក់រួចមកហើយនៅក្នុងសវនាការនេះ ដែលគាត់និយាយថា គេចាត់ទុកគាត់ជាវៀតណាម ហើយគេរើសអើងចំពោះគាត់ ពីព្រោះគាត់ត្រូវបានគេចាត់ទុកថាជាជនជាតិ

វៀតណាម។ ដូច្នេះខ្ញុំមិនអាចនិយាយអីឲ្យលើសពីហ្នឹងទៀតទេ។ ក៏ប៉ុន្តែយើងត្រូវតែសួរសំណួរខ្លួនឯងថា តើការប្រព្រឹត្តចំពោះខ្មែរក្រហមនោះ វាអាចផ្សាភ្ជាប់ទៅនឹងក្រុមប្រភេទផ្សេងម៉្យាងទៀត ហើយវាពាក់ព័ន្ធទៅនឹងការកំណត់ប្រភេទបទល្មើសក្នុងរឿងព្រហ្មទណ្ឌ ឬក៏យ៉ាងណា?

**ប្រធានអង្គជំនុំ៖**

បាទ ឥឡូវនេះកិច្ចប្រជុំរៀបចំសវនាការដែលធ្វើឡើងនៅរសៀលនេះ បានឈានដល់ទីបញ្ចប់ហើយ។ ហើយតាងនាមឲ្យអង្គជំនុំជម្រះសាលាដំបូង ខ្ញុំសូមថ្លែងអំណរគុណចំពោះសហព្រះរាជអាជ្ញា សហព្រះរាជអាជ្ញារង សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី មេធាវីការពារក្តី នួន ជា, ខៀវ សំផន, បុគ្គលិកអង្គជំនុំជម្រះសាលាដំបូង បុគ្គលិកសន្តិសុខ អ្នកបកប្រែភាសា និងបុគ្គលិកគាំទ្រនៃអង្គភាពផ្សេងៗទៀត ដែលបានខិតខំអស់ពីកម្លាំងកាយចិត្តជួយជ្រោមជ្រែងកិច្ចប្រជុំថ្ងៃនេះឲ្យទទួលបានជោគជ័យ។

អង្គជំនុំជម្រះនឹងលើកយកមតិយោបល់របស់ភាគីនានា ដែលលើកឡើងនៅក្នុងកិច្ចប្រជុំនេះទៅពិនិត្យពិចារណា ហើយអង្គជំនុំជម្រះនឹងចេញសេចក្តីសម្រេចទៅលើបញ្ហានេះឲ្យបានឆាប់បំផុតតាមដែលអាចធ្វើទៅបាន។ ហើយអង្គជំនុំជម្រះនឹងជម្រាបដល់ភាគីអំពីការផ្លាស់ប្តូរណាមួយទៅលើកាលបរិច្ឆេទស្តាប់សក្ខីកម្មសាក្សី សម្រាប់សប្តាហ៍ក្រោយតាមរយៈអ៊ីម៉ែលរបស់មន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូងនៅថ្ងៃស្អែក។

សម្រាកចុះ៕

*(កិច្ចប្រជុំផ្អាកនៅម៉ោង ១៥:៥១ នាទី)*